ព្រឹត្តិបត្រ មត៌កខ្មែរ
Morodok Khmer

លេខ ០១ ឆ្នាំទី ០១ ខែមីនា គ.ស. ២០១០ - ព.ស. ២៥៥៣

# ប្រាង្គប្រាសាទព្រះវិហារ ជាកេរមត៌ករបស់ខ្មែរ













ទាហានថៃ និងទាហានខ្មែរ កំពុងប្រុងជើងត្រៀមប្រយុទ្ធ នៅតំបន់ជម្លោះនៃប្រាសាទព្រះវិហារ

មាតិការឿង ទំព័រ


- វិបត្តិ និងដំណោះស្រាយ....................០៣
- ប្រវត្តិសង្ខេប នៃព្រះពុទ្ធសាសនា.........០៦
- គំនិតល្អក្នុងការផ្តល់ អត្ថន័យ..............០៧
- សីលធម៌របស់យុវវ័យ.........................១២
- អន្តោប្រវេសន៍យួន.............................១៥
- ព្រះរាជដំណើរទស្សនកិច្ច..................១៦
- ក្រសួងមហាផ្ទៃសារភាពថា.................២០
- គណៈប្រតិភូសហព័ន្ធខ្មែរ...................២២
- សន្និសីទរបស់ អ. ស. ប......................២៣
- កំពូលអាហារជួយលាងជាតិពុល........២៥
- រឿងរ៉ាវប្លែកៗនៅជុំវិញ.....................២៧


ប្រាសាទព្រះវិហារ មានទីតាំងនៅលើជួរភ្នំដងរែកត្រង់ព្រំប្រទល់ចុងបំផុត នៃប្រទេសកម្ពុជានិងប្រទេសសៀមស្ថិតលើទឹកដីខេត្តព្រះវិហារ។ ប្រាសាទនេះ តាំងនៅលើខ្ពង់រាបកំពស់៦២៥ ម៉ែត្រតាមផែនទី ភូមិសាស្ត្របារាំងបើតាមផែនទីភូមិសាស្ត្រអង់គ្លេសកំពស់៦១៦ ម៉ែត្រ (ផែនទីទាំងពីរនេះ សុទ្ធតែពោលជាម៉ែត្រដូចគ្នាទាំងអស់)។ ប៉ុន្តែអ្នកលេខារដ្ឋានបារាំងនិងអង់គ្លេសបានព្រមពៀងគ្នាសន្និដ្ឋានថា៖

**ក/** ខ្ពង់រាបពីខាងជើងទៅខាងត្បូងមានប្រវែង ៤០០ ទៅ ៥០០ ម៉ែត្រ។

**ខ/** តួប្រាសាទដែលសង់នៅត្រង់គែមខាងត្បូងបំផុត ពន្លួតទៅទិសខាងជើងដោយផ្ទាល់ទៅទល់នឹងខាងជើងបំផុត.......**(តទៅទំព័រទី៤)**

# មូលហេតុ
# ស្តីពីការចេញផ្សាយ នៃព្រឹត្តិប័ត្រ មត៌កខ្មែរ

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** នៃពុទ្ធិកសមាគមខ្មែរក្រោម វត្តខេមររង្សី នៅទីក្រុងសាន់ហូសេ្ស នឹងចេញផ្សាយតាមគេហទំព័រ http://www.unitedkhmerkrom.org និងបោះពុម្ពផ្សាយជារៀងរាល់ខែ ដើម្បីពង្រឹងពង្រីក វិស័យវប្បធម៌, ប្រពៃណី, ទំនៀមទម្លាប់, ភាសា, អក្សរសាស្ត្រជាតិ និងដំណឹងថ្មីៗ ពីសហគមន៍ខ្មែរ នៅក្នុងនិងក្រៅប្រទេស។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ផ្សព្វផ្សាយនូវសកម្មភាពសង្គម, ព័ត៌មានខ្មែរ-អន្តរជាតិ, អប់រំ, សុខភាព, កីឡា, រឿងរ៉ាវប្លែកៗ, សីលធម៌, ទស្សនៈកវី និងពុទ្ធសាសនាជាដើម....។ល។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** យកប្រាសាទព្រះវិហារធ្វើជាសញ្ញា (Logo) ដោយប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ហើយអង្គការយូនីស្កូ បានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ចេញផ្សាយជារៀងរាល់ខែ តាមគេហទំព័រ និងបោះពុម្ពចែកចាយដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០ នេះតទៅ។

សេចក្តីដូចបានប្រគេន-ជំរាបជូនដំណឹងខាងលើ សូមមិត្តអ្នកអាននៅក្នុងនិងក្រៅប្រទេស ជាពិសេសសហគមន៍ខ្មែរ នៅទីក្រុងសាន់ហូសេ្ស មេត្តាជ្រាបជាព័ត៌មាន និងគាំទ្រនូវដំណឹងថ្មីៗ ពីព្រឹត្តិប័ត្រ **មត៌កខ្មែរ** ដោយសោមនស្សរីករាយ។

បញ្ជាក់៖ លោក លោកស្រី ផ្សាយពាណិជ្ជកម្មជាមួយ ព្រឹត្តិប័ត្រ មត៌កខ្មែរ សូមទំនាក់ទំនង Tel: **(408) 923-2166**

ធ្វើនៅទីក្រុងសាន់ហូសេ្ស, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

គណៈកម្មការ **ព្រឹត្តិប័ត្រ** មត៌កខ្មែរ

---

## ព្រឹត្តិប័ត្រ មត៌កខ្មែរ

- ព្រះតេគុណ សឹង យ៉ឹង រតនា នាយកការផ្សាយ
- ព្រះតេជគុណ ថាច់ សុរិយា និពន្ធនាយក
- លោក អ៊ុក សុភ័ព្វ សម្រួលអត្ថបទ
- អ្នកស្រី គីលីន វីនីតា ពាណិជ្ជកម្ម
- លោក កោះ ថុន ពិនិត្យអត្ថបទ
- អ្នកស្រី បៃ សុផានី ផ្សព្វផ្សាយ
- លោក នឹង ស៊ិន ទីប្រឹក្សា

## អាសយដ្ឋានទំនាក់ទំនង

**ព្រឹត្តិប័ត្រ មត៌កខ្មែរ**

**MORODOK KHMER**

1594 Cunningham Ave.

San Jose, CA 95122. U.S.A

E-mail: morodokkhmer2010@gmail.com

Tel: (408) 923-2166/890-8877/550-5050

http://www.unitedkhmerkrom.org

# វិបត្តិ និង ដំណោះស្រាយ

ក្នុងជីវិតមនុស្សលោកយើងនេះ គ្មានអ្នកណាម្នាក់អាចរស់នៅបានសុខស្រួល ដោយគេចជៀសផុតពីវិបត្តិគ្រប់កាលវេលាបានទេ។សុខជាគូនិងទុក្ខ សប្បាយជាគូនិងព្រួយ ការបានលាភជាគូនិងការបាត់លាភ ។ នេះជាច្បាប់ធម្មជាតិ ដូចយប់និងថ្ងៃ ខ្មៅជាគូនិងរនោចផ្លាស់វេនគ្នាជារឿងធម្មតា ដូចយ៉ាងប្រទេសនានាក្នុងពិភពលោកទាំងមូល ដែលគ្មានសង្គ្រាមបង្ហូរឈាមគ្នាធំដុំត្រូវប្រឈម ក៏ស្រាប់តែមកប្រទះជាមួយនឹងឱនភាពសេដ្ឋកិច្ចជាសាកលធ្វើឲ្យមនុស្សម្នាមួយចំនួនធំមិនថាអ្នកធ្វើការឬអ្នកជំនួញ កំពុងជួបបញ្ហាលំបាកជាប្រវត្តិសាស្ត្រ ដែលមកទល់ពេលនេះ ពន្លឺនៃសេចក្តីសង្ឃឹមថាវិបត្តិត្រូវបានបញ្ចប់នោះហាក់នៅស្រពេចស្រពឹលនៅឡើយ។

វិបត្តិក្នុងសង្គមខ្មែរយើង ដែលនៅក្រៅមាតុភូមិនាពេលនេះ យើងសង្កេតឃើញថា មានវត្តអារាមមួយចំនួនកំពុងតែមានវិបត្តិនៃការបែកបាក់សាមគ្គីភាព ក្នុងចំណោមពុទ្ធបរិស័ទ ជាពិសេសគណៈកម្មការវត្ត។ ចំពោះព្រះសង្ឃ ដែលជាអ្នកបានតាំងចិត្តលះបង់ជីវិតធម្មតាៗ ដើម្បីសាងខ្លួនជាបុគ្គលបរិសុទ្ធប្រាសចាកកិលេស និង ព្យាយាមចាកចេញអំពីការជំពាក់ជំពិននឹងជីវភាពបុថុជ្ជន ដើម្បីក្លាយជាសាវ័ករបស់ព្រះពុទ្ធ មានតួនាទីផ្សព្វផ្សាយនូវព្រះធម៌ ដែលព្រះពុទ្ធអង្គបានចងក្រងទុកមក សម្រាប់ជាឱវាទនិងជាមធ្យោបាយឲ្យសត្វដែលមានទុក្ខចេះស្វែងរកឬសគល់នៃសេចក្តីទុក្ខ ដើម្បីកំចាត់ទុក្ខនោះចេញ ក្នុងការងារនេះ ព្រះសង្ឃភាគច្រើនបានបំពេញដោយពេញលេញ ឬមានការខ្វះខាតចន្លោះខ្លះទៅតាមនិស្ស័យរបស់លោក។ បើតាមការសង្កេត ដើម្បីអោយបានជាបុគ្គលបរិសុទ្ធគួរជាទីគោរពរបស់ពុទ្ធបរិស័ទ ព្រះសង្ឃលោកមានការអប់រំ និងតស៊ូផ្នែកផ្លូវចិត្តយ៉ាងខ្លាំងក្លាបំផុត។ ហើយយូរម្តងៗ យើងតែងលេចឮបញ្ហាខ្លះផ្ទុះចេញពីចំណោមបុគ្គល ដែលចាញ់សមរភូមិប្រយុទ្ធផ្ទៃក្នុង គឺត្រូវបែកធ្លាយភាពបរិសុទ្ធ។ បើយើងគិតថា ព្រឹត្តិការណ៍នេះជារឿងធ្ងន់ធ្ងរយ៉ាងណាក៏បាន ប៉ុន្តែនៅក្នុងសមរភូមិប្រយុទ្ធចម្បាំងរាំងជល់ដោយអាវុធក្តី ក្នុងការប្រលងប្រជែងនានាក្តី តែងមានឈ្នះមានចាញ់ មានជាប់មានធ្លាក់ជាធម្មតា យ៉ាងណាមិញសមរភូមិប្រយុទ្ធផ្លូវចិត្តក៏យ៉ាងនោះដែរ.

ដោយលែកនៅក្នុងយុគសម័យសម្ភារៈទំនើបមានការវិវដ្តខុសឆ្ងាយពីសម័យពុទ្ធកាលនោះ កំលាំងនៃការអូសទាញឲ្យភ្លាំងភ្លាត់ពីគន្លងធម៌ មានទំហំធំធេងណាស់ដែរ។ ព្រះបាទជ័យវរ្ម័នទី៧ ដែលជាស្តេចខ្មែរដ៏ល្បីរន្ទឺក្នុងប្រវត្តិសាស្ត្រនាសម័យមហានគរបានបន្សល់ទុកនូវពាក្យស្លោកដ៏មានខ្លឹមសារមួយឃ្លានោះគឺ«**ឈ្នះសត្រូវមួយពាន់នាក់ ឬមួយពាន់ដង មិនស្មើឈ្នះខ្លួនឯងម្តង**» ។

យោងលើខ្លឹមសារនៃពាក្យនេះ យើងក៏គួរតែកោតសរសើរចំពោះព្រះសង្ឃដែលបានថែរក្សាយ៉ាងខ្ជាប់ខ្ជួននូវធម៌វិន័យ ជាស្រែបុណ្យសម្រាប់ឲ្យពុទ្ធបរិស័ទបានបំពេញកងកុសលទាំងឡាយ ដោយនៅបរទេសនេះ អ្នកដែលសម្រេចដាច់ខាត លះបង់ជីវិតជាគ្រហស្ថទៅជាបព្វជិតក៏ពុំមានច្រើនប៉ុន្មានទេគឺមានការលំបាករកព្រះសង្ឃធ្វើបុណ្យណាស់ដែរ។ ព្រះសង្ឃខ្មែរមួយចំនួនមិនត្រឹមតែបានប្រកាន់ធម៌វិន័យខ្ជាប់នឹងខ្លួន និងបំពេញភារកិច្ចបំរើព្រះពុទ្ធសាសនាប៉ុណ្ណោះទេ លោកបានធ្វើការជួយដល់សង្គម ព្រមទាំងចូលរួមការពារសិទ្ធិមនុស្ស ទំនៀមទម្លាប់ ប្រពៃណីខ្មែរ រហូតដល់ហ៊ានតស៊ូប្តូរព្រះជន្ម ដើម្បីបុព្វហេតុជាតិទៀតផង តួយ៉ាងដូចព្រះសង្ឃដែលរស់នៅលើដែនដីកម្ពុជាក្រោមជាដើម។ចំពោះព្រះសង្ឃដែលភ្លាំងភ្លាត់ ខុសឆ្គងដោយចេតនាឬអចេតនានោះ យើងខ្ញុំមិនហ៊ានលើកមក........**(តទៅទំព័រទី១៨)**

(តមកពីទំព័រទី១)

នៃខ្ពង់រាប។

**គ**/ បើនៅខាងត្បូង គឺថានៅត្រង់ជើងនៃតួប្រាសាទ ខ្ពង់រាបមានសភាពចោទត្រង់មកលើនៃទីដីវាលកម្ពុជា ចំណែកឯត្រង់ទិសខាងជើងនៅទីបំផុត នៃខ្ពង់រាបដីទេរជំរាលទៅរកប្រទេសសៀម។ រឿងនេះហើយដែលនាំឲ្យអ្នកកសាងប្រាសាទពន្លួតថ្នល់ជណ្តើរមកពីខាងជើងទៅទិសត្បូង។

**ឃ**/ ខ្ពង់រាបមានសភាពរាបស្មើសុទ្ធសាធ។

**ង**/ ខ្ពង់រាបរាប់ចូលក្នុងជួរកំពូលភ្នំ ហើយតាំងនៅត្រង់បន្ទាត់ដែលបែងចែកទឹក។

ប្រាសាទព្រះវិហារមានអត្ថន័យថាៈ (**បុគ្គលជាទីគោរព**) ឬ (**អារាមជាទីគោរព**) ក្លាយមកពីភាសាសំស្រ្កឹត (**វិហារ**) បានរាប់បញ្ចូលក្នុងកេរ្តិ៍បេតិកភណ្ឌខាងសិល្បៈនិងខាងប្រវត្តិសាស្រ្ត។ប្រាសាទព្រះវិហារបានកសាងដោយព្រះ**បាទយសោវរ្ម័នទី១** ក្នុងរយៈឆ្នាំខាងចុងនៃសតវត្សរ៍ទី៩។ប្រាសាទនេះស្ថាបនាឡើង ដើម្បីឧទ្ទិសថ្វាយ **ព្រះសិខរីស្វរៈ** គឺថាព្រះ**សិវៈ** ជាអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត។ ប៉ុន្តែសព្វថ្ងៃនេះ ប្រាសាទទាំងមូលបានចុះកាលបរិច្ឆេទពីពាក់កណ្តាលសតវត្សរ៍ទី១១មក។

នៅពេលព្រះ**បាទសុរិយាវរ្ម័នទី១**ទ្រង់បានស្ថាបនាអំណាចដ៏យ៉ាងរឹងប៉ឹងលើប្រទេសកម្ពុជាហើយ ទ្រង់បានបញ្ជាឲ្យកសាងប្រាសាទធំៗ នៅព្រះបរមរាជវាំង ព្រមទាំងប្រាសាទនៅភ្នំជីសូរ និងព្រះវិហារ ដែលសំណង់បានចាប់ផ្តើមនៅឆ្នាំ១០១៨។ នៅទីបំផុតនៃសតវត្សរ៍ទី១១និងក្នុងរយៈឆ្នាំដំបូងសតវត្សរ៍ទី១២ ព្រះ**បាទជ័យវរ្ម័នទី៦**បានចាប់ផ្តើមកសាងសារជាថ្មីទៀត ហើយព្រះ**បាទសុរិយាវរ្ម័នទី២** ជាអ្នកកសាងប្រាសាទអង្គរវត្តនោះបានកសាងបន្តមកទៀត ក្នុងអំឡុង២៥ឆ្នាំនាដើមនៃសតវត្សរ៍ទី១២។ ការរៀបចំសំណង់ជាថ្មីឡើងវិញខ្លះៗដែលគេបានសង្កេតឃើញក្នុងព្រះវិហារនោះ ប្រាកដជាមានកាលបរិច្ឆេទនៅសម័យនៃការសាងសង់ផ្សេងៗពីគ្នានោះមែន។

សូមរំលឹកផងដែរថា នៅជាងពាក់កណ្តាលឆ្នាំ១៩៤០នោះ ប្រទេសសៀមបានលោភលន់ទាំងកំរោលទន្រ្ទានកាន់កាប់ប្រាសាទព្រះវិហារ ដោយខុសច្បាប់អន្តរជាតិម្តងមករួចហើយ។ លុះដល់ថ្ងៃ ១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការអន្តរជាតិនៅទីក្រុងឡាអេ កាត់ក្តីឲ្យពួកសៀមប្រគល់ប្រាសាទព្រះវិហារ មកឲ្យខ្មែរវិញជាបន្ទាន់ក្រោមព្រះរាជដឹកនាំរបស់ **សម្តេច នរោត្តម សីហនុ** និងសម្តេច បវរសេដ្ឋា **សឺន សាន** ព្រមទាំងមន្រ្តីជាន់ខ្ពស់ជាច្រើនរូបទៀតប្រកបដោយជោគជ័យ។

នៅក្នុងកិច្ចប្រជុំមួយ នាទីក្រុងកេប៊ិច ប្រទេសកាណាដា កាលពីថ្ងៃទី៧កក្កដាឆ្នាំ២០០៨នេះត្រូវបានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ បានសំរេចដាក់បញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ចំណុចនេះហើយដែលធ្វើឲ្យសៀម មានការក្តៅក្រហាយតវ៉ាជំទាស់ទាំងទទឹងទិស ដោយគ្មានសេចក្តីអៀនខ្មាសអ្វីសោះឡើយ ហើយវាបានប្រកាសជាសាធារណៈអោយមតិជាតិនិងអន្តរជាតិទទួលស្គាល់ថា ប្រាសាទព្រះវិហារជារបស់ពួកគេ រហូតដល់រដ្ឋាភិបាលសៀម បានបញ្ជូនកងទ័ពមកពង្រាយនៅលើទឹកដីខ្មែរទាំងបំពាន និងខុសច្បាប់នៅថ្ងៃទី១៥ កក្កដា ឆ្នាំ២០០៨។ ការលោភលន់របស់ប្រទេសសៀមមិនបានសម្រេចដូចបំណងឡើយដោយសារមានអង្គការជាតិ, អន្តរជាតិ និងបណ្តាប្រទេសនៅជុំវិញពិភពលោកបានស្គាល់ច្បាស់ថា ប្រាសាទព្រះវិហារជាកម្មសិទ្ធិរបស់ខ្មែរហើយនោះ។

សូមបញ្ជាក់ផងថា ព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ជាតិ ដូច្នេះព្រលឹងខ្មែរ អត្តសញ្ញាណជាតិ ជាប្រភពនៃការឯកភាពជាតិ និងជាគ្រឹះ សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ហេតុនេះយើងទាំងអស់គ្នា ត្រូវតែខិតខំអភិរក្ស និងស្ថាបនាប្រាសាទព្រះវិហារព្រមទាំង.......(**តទៅទំព័រទី២២**)




# ហាងខ្មែរលក់មាស ឡាក់គី

# LUCKY JEWELRY

- មានលក់ពេជ្រ HRD, GIA, IGI គ្រប់មុខ
- មាសសន្លឹក 24K 999, Canada Credit Swiss
- គ្រឿងត្បូង South - Sea Pearl គ្រប់ជំពូក
- មានគ្រឿងអលង្ការនាំចូលថ្មីៗពីបរទេស
- មានរចនាម៉ូដល្អៗទាន់សម័យនិយម
- ទិញចូលមានតម្លៃខ្ពស់
- លក់ចេញមានតម្លៃថោកសមរម្យ
- សូមអញ្ជើញអតិថិជនដោយមេត្រីភាព



- There are vast choices of models for HRD, GIA, IGI diamonds.

* 24K ... 999 flat-carded gold's are available from Canada Credit Swiss.
* All kind availabilities for gems and pearls from South-Sea Pearl.
* Newly imported jewelries from international countries.
* Modernize models are always updated.
* We buy your jewelries with high value offerings.
* We sell our jewelries with low, affordable pricing.
* **Please stop by, and we will guarantee your satisfaction**!

- **ម៉ោងធ្វើការៈ** Mon - Fri: 10:00am - 7:00pm

Tel: (408) 238-2098

- **2471 Alvin Ave. San Jose, CA 95121**

មានទទួល **Visa, Master Card** ៣ខែមិនគិតថ្លៃចុងការ

# មជ្ឈមណ្ឌលខ្មែរថែរក្សាភ្នែក SUNRISE

## Sunrise Medical-Dental Center

•មានវេជ្ជបណ្ឌិតស្ទាត់ជំនាញក្នុងការពិនិត្យភ្នែក។
•មានម៉ាស៊ីនទំនើបអាចវាស់ភ្នែកនិងកាត់កញ្ចក់វ៉ែនតា តាមតំរូវការ។
•មានវេជ្ជបណ្ឌិតនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ។






5710 Cahalan Avenue, Bldg.2
San Jose, CA 95123
Phone: (408) 227-6444
Fax: (408) 227-5056
www. Kasod.com

# ប្រវត្តិសង្ខេប នៃព្រះពុទ្ធសាសនា ចាប់កំណើតនៅលើទឹកដីសុវណ្ណភូមិ



ព្រះពុទ្ធទ្រង់ប្រោសបញ្ចវគ្គីយ៍ភិក្ខុ

ព្រះពុទ្ធសាសនាចាប់កំណើតឡើងនៅលើទឹកដីកម្ពុជាតាំងពីសតវត្សទី៥មកម្ល៉េះ ដោយមានប្រភពខ្លះបង្ហាញថា នៅសតវត្សទី៣នៃគ្រឹស្តសករាជ និងឯកសារខ្លះទៀតបង្ហាញថាព្រះពុទ្ធសាសនាថេរវាទត្រូវបាននាំចូលមកលើទឹកដីកម្ពុជា ក្នុងរាជព្រះបាទអសោក ដែលបានបញ្ជូនសមណទូត២អង្គព្រះនាមសោណត្ថេរ និងឧត្តរត្ថេរ មកកាន់ទឹកដីសុវណ្ណភូមិតាំងពីសតវត្សទី៣មុនគ្រឹស្តសករាជ។ សាសនានេះបានបន្តរីកចំរើនបន្តិចម្តងៗជាមួយនឹងព្រហ្មញ្ញសាសនាដូចមានសិលាចារឹកមួយនៅលើទឹកដីវៀតណាមសព្វថ្ងៃ គឺសិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាងចុះកាលបរិច្ឆេទនាសតវត្សទី៣ ដែលបាននិយាយពីព្រះមហាក្សត្រ គឺព្រះបាទស្រីមារ ទាក់ទងទៅនឹងពុទ្ធសាសនានេះផងដែរ។ ក្រៅពីការចូលមកកាន់ទឹកដីខ្មែរ តាមរយៈអ្នកផ្សព្វផ្សាយទាំងនោះពុទ្ធសាសនាក៏ត្រូវបានមកតាមរយៈពួកអ្នកជំនួញឥណ្ឌាផងដែរ។ ហើយចាប់ពីសតវត្សទី១៣រៀងមក លើកលែងតែនៅសម័យ ដែលខ្មែរក្រហមគ្រប់គ្រងអំណាចព្រះពុទ្ធសាសនានឹងបានក្លាយទៅជាសាសនារបស់រដ្ឋដែលមានពុទ្ធសាសនិកខ្មែរប្រមាណជិត៩៥% នៃប្រជាជនសរុប។

**ព្រះពុទ្ធសាសនានៅសម័យហ្វូណន**

អាណាចក្រហ្វូណន ពីសតវត្សទី២មុនគ្រឹស្តសករាជ រហូតដល់សតវត្សទី៦ នៃគ្រឹស្តសករាជបានកាន់នូវលទ្ធិហិណ្ឌូដោយមានព្រះមហាក្សត្រជាអ្នកដឹកនាំ និងមានជំនឿលើព្រះសិវៈ និងព្រះវិស្ណុ។ ទោះបីជាយ៉ាងនេះក្តីព្រះពុទ្ធសាសនា ក៏មានវត្តមានរួចជាស្រេចហើយនៅលើទឹកដីនៃអាណាចក្រនេះដែលជាសាសនាទី២បន្ទាប់ពីព្រាហ្មណ៍សាសនា។ រីឯព្រះពុទ្ធសាសនាមានភាពរីកចម្រើនរុងរឿងនៅអំឡុងសតវត្សទី៥-៦ នៃគ្រឹស្តសករាជក្នុងរជ្ជកាលព្រះបាទកៅឌិណ្ឌន្យវរ្ម័នព្រោះមានការបញ្ជូនព្រះសង្ឃខ្មែរ និងជាតិឥណ្ឌាទៅកាន់ប្រទេសចិន ដើម្បីយកឯកសារ និង ពុទ្ធរូបទៅថ្វាយដល់ស្តេចក្រុងចិន ហើយព្រមទាំងបានជួយបកប្រែគម្ពីរពីសំស្ក្រឹតទៅភាសាចិនទៀតផង។ ព្រះសង្ឃនាមសង្ឃបាលបានគង់នៅស្រុកចិន១៦ឆ្នាំ ព្រមទាំងបានទទួលងារជាព្រះរាជគ្រូរបស់ចិនទៀតផង នេះក៏ព្រោះតែមានចំណេះដឹងផ្នែកសាសនារបស់ព្រះអង្គ។

**ព្រះពុទ្ធសាសនាសម័យចេនឡា:** នៅសម័យហ្វូណនព្រះពុទ្ធសាសនានៅរុងរឿងគួរសមនៅឡើយ។ លុះដល់ចុងសតវត្សទី៧តាមសង្ឃដីការបស់ព្រះសង្ឃចិនមួយអង្គព្រះនាមយ៉ីសិង ដែលបាននិមន្តត្រឡប់ពីប្រទេសឥណ្ឌា ទៅកាន់ប្រទេសចិនកាត់តាមរាជាណាចក្រចេនឡាឱ្យដឹងថាពីដើមឡើយ...**(តទៅទំព័រទី១១)**

# គំនិតល្អក្នុងការផ្តល់ អត្ថន័យដល់ជីវិត

ការរស់នៅប្រចាំថ្ងៃ ត្រូវប្រឈមមុខទាំងរឿងល្អ និងអាក្រក់ មកលាយឡំជាមួយគ្នាធ្វើឱ្យលំបាករកវិធីដោះស្រាយមិនចេះអស់ មិនចេះហើយ។រឿងទាំងនោះនឹងបានផ្តល់ជាបទពិសោធន៍សម្រាប់ឆាកជីវិតមនុស្សទូទៅទាំងអស់ ដើម្បីជៀសឲ្យផុតពីភាពស្មុគ្រស្មាញនេះបាន ត្រូវសិក្សា និងពិចារណានូវគំនិតល្អៗទាំង១០ប្រការដូចខាងក្រោមនេះៈ

១-ជាការពិត សម្ព័ន្ធមិត្តភាពមិនមានថ្ងៃសាបសូន្យឡើយ ប៉ុន្តែអ្នកអាចនឹងភ្លេចខ្លួនថា មិត្តភាពអាចប្រែប្រួលបានទៅតាមកាលៈទេសៈនិង បរិយាកាសនៃសង្គមជាតិឬបញ្ហាផ្សេងៗដែលកើតមានចំពោះខ្លួនឯងផ្ទាល់ព្រមទាំងអ្នកដទៃជាដើម។

២-នៅពេលអ្នកដឹងថា មិនមានអ្នកណាម្នាក់ជួយសង្គ្រោះ ក្នុងកាលៈទេសៈដែលអ្នកមានទុក្ខ គ្មាននរណាចិត្តល្អពិតប្រាកដ ជាមួយអ្នកនៅពេលអ្នកមានសេចក្តីសុខពេលនោះអ្នកនឹងស្វែងយល់ក្នុងការរកមិត្តចិត្តស្មោះជាមួយអ្នកបានហើយ។

៣-អតីតកាលជារឿងដែលកន្លងផុតទៅហើយ អ្នកត្រូវតែជម្រុះចោលការឈឺចាប់គ្រប់យ៉ាង ដែលបានជួបប្រទះទៅតាមអតីតកាលនោះផងទៅ។

៤-កុំព្រងើយកន្តើយបោះបង់ចោលមនុស្ស ដែលអ្នកស្រឡាញ់ពេញចិត្តអោយសោះ. កុំចេះតែបណ្តែតបណ្តោយអោយមេត្រីភាពនោះសាបសូន្យ ព្រោះជីវិតមនុស្សគឺខ្លីណាស់នឹងស្លាប់ថ្ងៃណាមួយក៏មិនដឹងដែរ។

៥-អ្នកមិនត្រូវស្លាប់ព្រោះតែក្តីឈឺចាប់ក្នុងឆាកជីវិត ដែលកន្លងផុតទៅហើយទេ ប៉ុន្តែនោះធ្វើឱ្យអ្នករឹតតែរឹងប៉ឹងឡើង។

៦-គួរកុំឱ្យខ្សែជីវិតអ្នករស់ពឹងផ្អែក លើអ្នកដទៃ ព្រះពុទ្ធបានសម្តែងមកថា **អត្តាហិ អត្តនោ នាថោ** ខ្លួនទីពឹងខ្លួន កាលបើមានជីវិត ត្រូវមានការតស៊ូ ចេះរស់ដោយខ្លួនឯង ការដែលពឹងអាស្រ័យគេបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ មិនមានស្ថេរភាពឡើយ។

៧-ជីវិតអាពាហ៍ពិពាហ៍ និង គ្រួសារជារឿងសំខាន់ចូរកុំរួសរាន់សម្រេចចិត្តងាយស្រួលៗពេក។ ពាក្យចាស់បុរាណពោលថា ធ្វើស្រែខុសមួយរដូវ តែបើទុកដាក់កូនចៅបើខុសៗមួយជីវិតដូច្នេះត្រូវចំណាយអោយបានច្រើនសម្រាប់ស្វែងយល់ជីវិតពិតរបស់ខ្លួនឯង និងអ្នកដែលខ្លួនស្រឡាញ់ជាមុនសិន ចាំសម្រេចចិត្តជាខាងក្រោយ ទើបសុភមង្គលអាចនឹងកើតមានយ៉ាងប្រាកដនោះ។

៨-យើងត្រូវសម្តែងការរីករាយពេញចិត្ត ចំពោះមនុស្សដែលអ្នកស្រឡាញ់ជារៀងរាល់ថ្ងៃ មិនមែនចេះតែព្រួយបារម្ភពីគេតែថ្ងៃបុណ្យ ឬថ្ងៃខួបកំណើតនោះទេ ត្រូវចេះធ្វើការទំនាក់ទំនងនិងចូលរួមផ្តល់ជាកម្លាំងចិត្ត ឬសម្តែងភាពស្មោះត្រង់ជាមួយគេផងដែរ។

៩-មនុស្សឯទៀតជាច្រើនបានមកពាក់ព័ន្ធក្នុងជីវិតអ្នកដោយមានហេតុផលច្បាស់លាស់ និងឱកាសដែលនាំមកនូវសេចក្តីសុខ ព្រមទាំងមេរៀននៃជីវិតសំរាប់អ្នក ហេតុនេះយើងត្រូវចេះរក្សាចំណងល្អទាំងនេះឲ្យបានស្ថិតស្ថេរ និងស្មោះអស់ពីដួងចិត្តចំពោះកាយវិការដ៏ប្រពៃនេះផង។

១០-គ្រប់ពេលដែលខកចិត្តអស់សង្ឃឹម អ្នកត្រូវមើលពិភពលោក ក្នុងផ្លូវល្អឱ្យបានច្រើន មានជីវិតត្រូវសង្ឃឹម មិនត្រូវអស់មុនពេលជីវិតរស់នៅឡើយ។

អត្ថន័យទាំង១០ប្រការនេះគឺគន្លឹះសម្រាប់ធ្វើជាមេរៀន ដើម្បីកសាងសង្គមជាតិ និងខ្លួនឯងផ្ទាល់ ក្នុងទិសដៅ ឆ្ពោះទៅរកត្រើយសន្តិភាពនិងសុភមង្គល នាពេលបច្ចុប្បន្ន-អនាគត៕

**ដោយ ថាច់ ចន្ទ្រា**

# វិធីដើម្បីស្ងប់ផ្លូវចិត្ត

ក្នុងខណៈដែលពុទ្ធបរិស័ទគ្រប់រូប មានអារម្មណ៍ពុះពោរទៅដោយកំហឹង មើលឃើញអ្វីៗនៅជុំវិញខ្លួនសុទ្ធតែខ្មៅងងឹតនោះស្ថានភាពនេះ ផាយនឹងបង្កសេចក្តីអន្តរាយខ្លាំងណាស់។ ហេតុនេះ គួរខិតខំប្រឹងប្រែងព្យាយាមរំលត់នូវហិង្សាទាំងប៉ុន្មាន ដែលបានជាប់ជំពាក់ក្នុងខ័ន្ធសន្តានរបស់ខ្លួនតាមវិធី១០យ៉ាងដូចខាងក្រោមនេះ......។

**១-រាប់ពីមួយដល់ដប់**

ចាប់ផ្តើមវិធីដំបូង គឺយើងរាប់លេខក្នុងចិត្តពេលដែលយើងខឹងអ្នកណាម្នាក់ យើងត្រូវរាប់ពីមួយដល់ដប់ ឬលើសពីដប់ទៅក៏កាន់តែល្អប្រសើរ ព្រោះការរាប់លេខធ្វើឱ្យយើងមានសមាធិ(គឺសេចក្តីស្ងប់កាយស្ងប់ចិត្ត) ហើយថែមទាំងមានពេលពិចារណាគិតដល់អ្វី ដែលអ្នកដទៃបានធ្វើជាមួយយើងកន្លងមកនោះ។

**២-កុំអំពល់ទុក្ខ**

បញ្ហាដែលកើតឡើងជារាល់ថ្ងៃនេះមួយភាគដោយសារតែយើងគិតពីខ្លួនឯងច្រើនពេក ប្រសិនបើយើងផ្លាស់ប្តូរការគិតកុំឲ្យជាប់ជំពាក់វិលវល់ក្នុងវដ្តសង្សារ ពេលនោះមិនថារឿងធំឬរឿងអ្វីៗនោះទេ ក៏អាចក្លាយទៅរឿងតូចតាចបានទាំងអស់។

**៣-គួរចេះបំភ្លេចទុក្ខ**

ដើម្បីបំភ្លេចសេចក្តីទុក្ខបាននោះទាល់តែយើងរាល់គ្នា ប្រកាន់យកផ្លូវកណ្តាលគឺឧបេក្ខាមកទុកនៅក្នុងសតិអារម្មណ៍ ឬ ចិត្តគំនិតរបស់ខ្លួនជាមុនសិន ហើយព្យាយាមសិក្សាព្រះធម៌ និងដើរកំសាន្តនៅទីណាមានបរិយាកាសល្អ ជាពិសេសធ្វើចិត្តឲ្យទូលំទូលាយ គិតតែអំពើជាកុសល ហើយតាំងចិត្តជាសមាធិ។

**៤-គិតច្រើនពេកទេដឹង**?

ការគិតច្រើន ជាចំណែកមួយធ្វើឱ្យកើតជម្ងឺស្ត្រេសបាន បើមានរឿងរ៉ាវយ៉ាងនេះយ៉ាងនោះ ហើយចេះតែយកមកគិតរហូតដល់ដេកមិនលក់បក់មិនល្ហើយនោះ សាកប្តូរគិតពីរឿងពិបាកទៅជារឿងស្រួលៗវិញមើល ពីព្រោះការគិតនោះ ជាផ្លូវកំណត់នៃជីវិតរបស់យើង ។

**៥-ហាត់សមាធិ**

ការធ្វើសមាធិឱ្យចិត្តស្ងប់នោះ មានច្រើនវិធីណាស់ ចង់ដើរ ឬ អង្គុយធ្វើសមាធិក៏បាន។ ការហាត់ធ្វើសមាធិនេះ មានសារប្រយោជន៍សំរាប់អប់រំផ្លូវចិត្តឲ្យមានសទ្ធា និងព្រហ្មវិហារធម៌ ជាពិសេសប្រាសចាកនូវអកុសលធម៌ជាដើម។

**៦-ស្គាល់គេស្គាល់ឯង**

ជួនកាលយើងគ្រាន់តែសំឡឹងមើលនិងសិក្សាពីទម្លាប់ពីអ្នកជិតខាងយើង ហើយពិចារណានូវហេតុផលច្បាស់លាស់ជាមុន ក៏អាចរស់នៅក្នុងសង្គមជាមួយគេបាន ប៉ុន្តែយើងត្រូវចេះរម្ងាប់អារម្មណ៍ និងប្រកាន់យកភាពស្មោះត្រង់ត្រូវចេះសំរបខ្លួនតាមកាល។ **(តទៅទំព័រទី៩)**

(តមកពីទំព័រទី៨) ហើយយើងអាចជ្រាបបានថាគេជាមនុស្សប្រភេទយ៉ាងណាៗ ប្រសិនបើយើងទទួលយកមិនបានអ្នកត្រូវរស់នៅឆ្ងាយពីគេទើបប្រសើរ ហើយអាចចៀសឆ្ងាយពីបញ្ហាទៀតផង។

**៧-សុំទោសគឺជាពាក្យប្រើបានរហូត**

ប្រសិនបើយើងធ្វើខុសឆ្គងដោយកាយវិការណាមួយទៅលើបុគ្គលណាម្នាក់នោះ ការប្រើនូវពាក្យសុំទោសនោះវាជារឿងល្អបំផុត មិនមែនជារឿងពិបាកទេ ព្រោះពាក្យនេះមិនធ្វើឱ្យយើងអាប់ឱនដែរ ឱ្យតែយើងទទួលស្គាល់កំហុសដែលខ្លួនបានប្រព្រឹត្តថែមទាំងសូមឱ្យស្ថានការណ៍អាក្រក់ក្លាយជាល្អបាន។ យើងមិនគួរប្រើពាក្យបែបប៉ាច់ប៉ោចទេ ព្រោះជាទំលាប់មិនល្អ ធ្វើអ្វីត្រូវចេះប្រយ័ត្នប្រយែងខ្លួនទើបទទួលបានជោគជ័យក្នុងឆាកជីវិត។

**៨-ញញឹមជានិច្ច**

ស្នាមញញឹមអាចធ្វើឱ្យខ្លួនយើងនិងពិភពលោកនេះស្រស់ស្អាតបាន ប្រៀបដូចពាក្យថា "**បើអ្នកញញឹមដាក់ពិភពលោកនោះពិភពលោកក៏ញញឹមរកអ្នកវិញដែរ**" ទោះបីយើងទៅរស់នៅកន្លែងណាឬ ទៅបំពេញកិច្ចការក្នុងស្ថាប័នណាមួយនោះ យើងត្រូវចេះសំរបសំរួលឥរិយាបថ និងភាពរុះរាយ ប្រកបដោយស្នាមញញឹម ដែលផុសចេញពីបេះដូងពិតៗ ដើម្បីធ្វើឲ្យបរិយាកាសនៅជុំវិញខ្លួនមានសោភណភាពល្អនិងអាចទាក់ទាញអារម្មណ៍អ្នកដទៃឲ្យមានទឹកចិត្តសប្បាយផងដែរ។

**៩-ដកដង្ហើមវែងៗ**

ការដកដង្ហើមចេញចូលវែងយូរៗ នឹងធ្វើឱ្យយើងមានសតិគិតរឿងរ៉ាវ ដែលកើតឡើងហើយធ្វើឱ្យរាងកាយអាចបន្ធូរបន្ថយពីកំហឹង។ដូច្នេះមុននឹងសម្រេចចិត្តធ្វើអ្វីក្នុងពេលដែលមានអារម្មណ៍មិនល្អឬកំពុងខឹងនឹងបុគ្គលណាម្នាក់នោះ យើងត្រូវតែរកទីកន្លែងណាមួយ មានខ្យល់អាកាសល្អ ហើយសាកល្បងដកដង្ហើមចូលវែងៗ ហើយដកដង្ហើមចេញយឺតៗពេលនោះអារម្មណ៍របស់យើងនឹងភ្លឺថ្លាជាក់ជាមិនខាន។

**១០ - មិនគេចវេះ**

ប្រសិនបើយើងមិនអាចដោះស្រាយបញ្ហាចំពោះមុខបាន ហើយដើរចេញគឺជាការមិនព្រមទទួលយកជាតុពិតដែលខ្លួនបានធ្វើឬត្រូវគេចោទប្រកាន់។ ដូច្នេះត្រូវប្រើសតិពិចារណាឱ្យគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយរឿងរ៉ាវនិងស្តាប់គំនិតពីអ្នកដទៃផងទើបជាការប្រសើរ។

វិធីដើម្បីរម្ងាប់ផ្លូវចិត្តទាំង១០ប្រការដូចពោលមកនេះគ្រាន់តែជាគតិមួយសម្រាប់ឲ្យពុទ្ធបរិស័ទសិក្សានិងពិចារណារកហេតុផលក្នុងការរក្សាអារម្មណ៍ឲ្យមានលំនឹងល្អប៉ុណ្ណោះ។ **ដោយ ថាច់ ចន្ទ្រា**




# សេចក្ដីជូនដំណឹងជាសាធារណៈ

## ការជំរឿនប្រជាជន ឆ្នាំ២០១០

CENSUS 2010 OUTREACH

យើងខ្ញុំ សូមគោរពអញ្ជើញ អស់លោក លោកស្រី មកចូលរួមកិច្ចប្រជុំស្ដីពីការជំរឿនប្រជាជនគ្រប់សញ្ជាតិទាំងអស់ ដែលកំពុងរស់នៅសហរដ្ឋអាមេរិក ដោយសាររដ្ឋាភិបាលបានចេញច្បាប់ឱ្យមានការធ្វើជំរឿនប្រជាជនរៀងរាល់១០ឆ្នាំម្ដង។

សមាគមស្ត្រីខ្មែរ សង្កាត់ **Santa Clara** សហការជាមួយបុគ្គលិកខ្មែរ ធ្វើការនៅសាលាក្រុង San Jose បើកកិច្ចប្រជុំ ដែលមានអាសយដ្ឋានដូចខាងក្រោម៖

**Date:** Saturday, March 6th, 12:30pm-4:00pm

**Location:** Santee Action Center, 1535 Santee Drive, San Jose, CA 95122.

**Date:** Sunday, March 14th, 12:30pm-4:00pm

**Location:** Watt Khmer San Jose, 840 Mervyn′s Way, San Jose , CA 95127.

Documentary Film: **Sleepwalking Through The Mekong**

***បញ្ជាក់៖*** សមាគមស្ត្រីខ្មែរ នឹងមានចែកជូនអាវយឺត(T-Shirt) និងមានម្ហូបអាហារ ជូនលោកអ្នកពិសារដោយឥតគិតថ្លៃ។ ***សូមលោកអ្នកអញ្ជើញចូលរួមកម្មវិធីដ៏ពិសេសនេះឱ្យបានច្រើនកុះករ ពីព្រោះ១០ឆ្នាំមានតែម្ដង !!!***

**Contact Persons:** Channary Bill: ( 408 ) 252-8405, **Jennifer Chan**: ( 408 ) 629-8734 **Teur Say**: ( 408 ) 277-2980

# *ដំណឹងសិក្សា*
## *ភាសាខ្មែរ និងរបាំប្រពៃណីបុរាណខ្មែរ*

*ពុទ្ធិកសមាគមខ្មែរក្រោម **វត្តខេមររង្សី** និងក្រុមរបាំអប្សរា នៅទីក្រុងសាន់ហូសេ្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនជនរួមជាតិខ្មែរ គ្រប់មជ្ឈដ្ឋាន ឲ្យបានជ្រាប សូមទានជ្រាប ៖*

*** *កម្មវិធីសិក្សាភាសាខ្មែរ ជារៀងរាល់ថ្ងៃសុក្រ និងសៅរ៍ ចាប់ពីម៉ោង* **4:00PM - 5:00PM**

*** *កម្មវិធីបង្ហាត់របាំប្រពៃណីខ្មែរ ជារៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង* **6:00PM - 8:00PM**

*អាស្រ័យហេតុនេះ សូមអញ្ជើញអាណាព្យាបាល និងសិស្សានុសិស្ស គ្រប់ស្រទាប់វណ្ណៈ ដែលមានទឹកចិត្តស្រឡាញ់ និងលើកស្ទួយវិស័យវប្បធម៌ខ្មែរ មេត្តារួសរាន់នាំបុត្តធីតារបស់លោក អ្នក មកសិក្សាភាសាខ្មែរ និងរបាំប្រពៃណីជាតិ ដោយសោមនស្សរីករាយ។*

*** ***ទីកន្លែង:*** *វត្តខេមររង្សី* **1594 Cunningham Ave, San Jose. CA 95122 Tel: (408) 923-2166**

(តមកពីទំព័រទី៦)

ព្រះធម៌មានភាពរុងរឿងណាស់ ហើយបានផ្សព្វផ្សាយគ្រប់ទិសទី តែឥឡូវនេះស្តេចកំណាចមួយអង្គបានបំផ្លិចបំផ្លាញចោលអស់ ហើយព្រះសង្ឃរកតែមួយអង្គនិមន្តមិនបានផង (ត្រឹងងាប្រវត្តិសាស្ត្រខ្មែរភាគ ១+២, ១៩៧៣)។ តាមរយៈនេះឃើញថាព្រះពុទ្ធសាសនាត្រូវបានសាបរលាបនូវឥទ្ធិពលរបស់ខ្លួន នៅក្នុងសតវត្សនេះប៉ុន្តែមិនមែនមានន័យថាបាត់បង់ទាំងស្រុងនោះទេ ផ្ទុយទៅវិញនៅសតវត្សរ៍ក្រោយមកពុទ្ធសាសនាមហាយាន បានចាប់ផ្តើមផ្សាយឥទ្ធិពល របស់ខ្លួននិងមានប្រជាពលរដ្ឋបានគោរពខ្លះៗហើយ។ នៅសម័យនេះមានសិលាចារិកតែមួយគត់ ដែលបាននិយាយពីព្រះភិក្ខុពុទ្ធសាសនាចំនួនពីរអង្គ។

### ព្រះពុទ្ធសាសនាសម័យអង្គរ

បន្ទាប់ពីការទ្រុឌទ្រោម នៃលទ្ធិពុទ្ធសាសនាហីនយាននៅសម័យចេនឡានាកំឡុងសតវត្សទី៧មក ពុទ្ធសាសនាមហាយានបានចាប់ផ្តើមកើតឡើង រហូតដល់សម័យអង្គរ។នៅក្នុងសតវត្សទី៩រជ្ជកាលព្រះបាទជ័យវរ្ម័នទី២ មានការប្រារព្ធធ្វើពិធីទេវរាជនៅលើភ្នំគូលែន ដែលអាចបង្ហាញថាព្រះរាជាអង្គនេះមានជំនឿយ៉ាងមុតមាំចំពោះព្រហ្មញ្ញសាសនាដែលមានឥទ្ធិពលខ្លាំងក្លានៅសម័យនោះនិងមានការគោរពរាប់អានខ្លាំងពីប្រជារាស្ត្រខ្មែរ។ តែទោះជាយ៉ាងណាក្តីក៏ពុទ្ធសាសនាមហាយានបានបន្តវត្តមានរបស់ខ្លួនដដែល នៅលើទឹកដីខ្មែរលាយឡំជាមួយនឹងលទ្ធិព្រាហ្មផងដែរ។តាមរយៈឯកសារខ្លះបានបង្ហាញថា ពុទ្ធសាសនាបានរីកចំរើន និង មានការទទួលស្គាល់បន្តិចម្តងៗ ពីប្រជារាស្ត្រនិងព្រះមហាក្សត្រខ្មែរបន្តបន្ទាប់មក។ នៅសតវត្សទី៩ ក្នុងរាជព្រះបាទយសោវរ្ម័នទី១ មានការសាងសង់បារាយណ៍ខាងកើតឈ្មោះ**យសោធរ** ដាក់នៅភាគខាងកើតលើច្រាំងនៃបារាយណ៍នេះ មានការសាងសង់បន្ថែមទៀតនូវអាស្រមសំរាប់គណៈសាសនា នៅសម័យនោះដូចជា៖

- ព្រាហ្មណាស្រម សម្រាប់អ្នកកាន់និកាយព្រះឥសូរ
- វៃស្នវាស្រម សម្រាប់អ្នកកាន់និកាយព្រះវិស្ណុ។
- សៅគតាស្រម សម្រាប់អ្នកកាន់សាសនាព្រះពុទ្ធ

តាមរយៈនេះឃើញថា នៅសម័យនោះពុំមានការហាមឃាត់ មិនឱ្យគោរពព្រះពុទ្ធសាសនានោះទេ ទោះបីព្រាហ្មណ៍សាសនាមានការរីកចម្រើនខ្លាំងក៏ដោយហើយ ព្រះមហាក្សត្រមានការបើកចំហចំពោះប្រជាជនឱ្យមានសិទ្ធិក្នុងការគោរពសាសនានោះដែរ។ តាមប្រវត្តិសាស្ត្ររបស់ខ្មែរយើងសម័យអង្គរបានបង្ហាញទៀតថានាសម័យអង្គរ ព្រះពុទ្ធសាសនាមហាយានបានចាប់ផ្តើមរុងរឿងនៅក្នុងរាជ្យរបស់ក្សត្រមួយចំនួន។

- **រាជព្រះបាទសូរ្យវរ្ម័នទី១**

ព្រះបាទសូរ្យវរ្ម័នទី១ ជាបឋមក្សត្រខ្មែរទី១ នៃសម័យអង្គរ ដែលបានលើកតម្កើងព្រះពុទ្ធសាសនាឱ្យថ្កុំថ្កើងរុងរឿង។ ព្រះអង្គទ្រង់គ្រងរាជសម្បត្តិនៅកំឡុងឆ្នាំ(១០០២-១០៥០)ជាពុទ្ធសាសនិកដ៏ឆ្នើមដែលបានគាំទ្រ និង លើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលរាប់អានចំពោះព្រះពុទ្ធសាសនា លើសពី.....**(តទៅទំព័រទី១៣)**

# សីលធម៌របស់យុវវ័យបច្ចុប្បន្ន

សីលធម៌រស់នៅរបស់យុវវ័យខ្មែរសព្វថ្ងៃនេះត្រូវបានគេសង្កេតឃើញថា មួយចំនួនកំពុងប្រព្រឹត្តខុសចាកគន្លងសីលធម៌ វប្បធម៌ប្រពៃណីជាតិ ដូចជាការប្រើអំពើហិង្សាមិនគោរពតាមការប្រៀនប្រដៅរបស់ឪពុកម្តាយគ្រូបង្រៀនជាដើម. អ្នកចាស់ទុំខ្មែរមួយចំនួន ទាំងនៅទីក្រុងភ្នំពេញ និងតាមខេត្តនានាបានសម្តែងការរិះគន់ថា សីលធម៌រស់នៅរបស់យុវជនយុវតីខ្មែរមួយចំនួនសព្វថ្ងៃនេះ គឺបានប្រាសចាកឆ្ងាយពីគន្លងដើមបើគេប្រៀបធៀបទៅនឹងសីលធម៌រស់នៅរបស់យុវវ័យខ្មែរកាលពីជំនាន់មុនៗ។

ការរិះគន់នេះបន្ទាប់ពីគេបានឃើញនូវសកម្មភាពទាំងឡាយរបស់យុវវ័យខ្លះ បានធ្វើអំពើមិនល្អជាបន្តបន្ទាប់ ដូចជាការប្រើហិង្សាឈ្លោះប្រកែកវាយតប់ បាញ់ចាក់កាប់សម្លាប់គ្នានៅក្នុងពិធីរាំវែកនៃពិធីមង្គលការឬពិធីបុណ្យទានហើយប្រមាថមាក់ងាយ មិនស្តាប់នូវពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយ ឬគ្រូបង្រៀននៅក្នុងសាលា នាំគ្នាសេពគ្រឿងញៀន គ្រឿងស្រវឹង ឬក៏ដើរលេងគេចវេះមិនចូលរៀន។ល។

ក្នុងចំណោមអ្នកចាស់ទុំទាំងនោះមានស្ត្រីចាស់ទុំខ្មែរមួយរូបនៅទីក្រុងភ្នំពេញ ឈ្មោះ គឹម ស៊ីមឿន បានបញ្ជាក់ប្រាប់ពីសីលធម៌យុវវ័យក្នុងអំឡុងទសវត្សរ៍ទី៦០ថា កាលនោះគឺក្មេងៗភាគច្រើនណាស់មានការប្រព្រឹត្តខ្លួនល្អ ចេះគោរពកោតក្រែងនិងស្តាប់ការទូន្មានរបស់ឪពុកម្តាយជីដូនជីតា មានភាពគួរសមឱនលំទោនដល់ចាស់ព្រឹទ្ធាចារ្យនិងគោរពគ្រូបាអាចារ្យ ព្រមទាំងញាតិមិត្តជិតខាងរបស់ខ្លួនជាដើម។

អ្នកស្រី គឹម ស៊ីមឿន មានប្រសាសន៍បន្តដូច្នេះ៖«*ឥឡូវនេះខុសគ្នាឆ្ងាយណាស់គ្រូបង្រៀនស្រួលមិនស្រួលវាអាចមើលងាយ មើលស្រាលលោកគ្រូទៀត*»។

ការធ្លាក់ចុះសីលធម៌របស់យុវវ័យក្នុងសម័យបច្ចុប្បន្ន ក្រៅពីចាស់ទុំនៅទីក្រុងភ្នំពេញ បានសម្តែងការព្រួយបារម្ភនោះ ក៏មានប្រជាពលរដ្ឋផ្សេងទៀតនៅតាមខេត្តនានាបានសម្តែងក្តីបារម្ភដូចគ្នានេះដែរ។

បុរសមួយរូបឈ្មោះ ញ៉ែម សុខ នៅភូមិសមរ ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានប្រាប់ឲ្យដឹងថា កូនចៅក្មេងៗក្នុងជំនាន់នេះ ក្នុងតំបន់របស់គាត់គឺភាគតិចណាស់ដែលចេះគោរពកោតក្រែងឪពុកម្តាយក្រៅពីនេះគេច្រើនតែបង្កការលំបាកក្នុងគ្រួសារ មិនសូវចង់រៀនសូត្រឬក៏ធ្វើការងារអ្វីឡើយ៖«តាមតែសង្គមវាបបួលអីចឹងតែម្តង។ យប់ថ្ងៃអីវាដើរលេងអត់សូវស្តាប់ម៉ែឪ»

គ្រូបង្រៀនមួយរូបសុំមិនប្រាប់ឈ្មោះនៅខេត្តព្រះសីហនុ បានបញ្ជាក់ប្រាប់ដែរថា កូនសិស្សក្នុងសម័យនេះគឺមិនសូវមានការគោរព ឬស្តាប់ការបង្រៀនរបស់គ្រូទេជាពិសេសគឺកូនចៅអ្នកមានធនធាន ៖ «ឧទាហរណ៍ ជាក់ស្តែង ដូចយើងបង្រៀនអីចឹង គេចង់មករៀនក៏មកទៅមិនចង់ក៏ហីទៅ។ កត្តាដែលធ្វើឲ្យអត់ខ្លាចគ្រូគឺទី១ប្រាក់បៀវត្សមានកម្រិតទាបពេក អីចឹងគ្រូចង់មិនចង់ត្រូវតែសម្រេចចិត្តទៅធ្វើអ្វីមួយ ដើម្បីបំពេញជីវភាព។គ្រូអត់លក់នំគ្រូអត់បង្រៀនគួរវាអ៊ីចឹងសេចក្តីថ្លៃថ្នូររបស់គ្រូបាត់អស់រលីង ដោយសារកត្តាទាំងប៉ុន្មានហ្នឹង»។

ក្រៅពីមនុស្សវ័យចាស់ ឬគ្រូបង្រៀនបានកត់សម្គាល់ឃើញថា យុវវ័យក្នុងសម័យនេះមានការយល់ដឹងផ្នែកសីលធម៌មាន**(តទៅទំព័រទី១៩)**

(តមកពីទំព័រទី១១)

នេះ ពុទ្ធសាសនាថេរវាទត្រូវបានព្រះអង្គនឹងធ្វើការផ្សព្វផ្សាយឱ្យកាន់តែរុងរឿង ហើយបានតម្កើងសាសនានេះជាសាសនារបស់រដ្ឋ។ទោះជាព្រះអង្គបានបង្ហាញពីទឹកចិត្តរបស់ព្រះអង្គ ដែលគោរពស្រឡាញ់ចំពោះពុទ្ធសាសនាក៏ដោយចុះតែព្រះអង្គក៏នៅតែមេត្តាដល់សាសនាព្រាហ្មណ៍ផងដែរ ដោយនៅសម័យនោះអ្នកកាន់ព្រះពុទ្ធសាសនា និងអ្នកកាន់សាសនាព្រាហ្មណ៍បានរស់នៅជាមួយគ្នាដោយសុខសាន្ត តាមសិលាចារិកបានបង្ហាញអំពីទឹកចិត្តរបស់ព្រះអង្គគោរពស្រឡាញ់ចំពោះពុទ្ធសាសនាទាំងពីរនិកាយគឺៈ ហិនយាន និងមហាយាន ដោយព្រះអង្គបានផ្លាស់ប្តូរតួនាទីរបស់គ្រូសារព្រាហ្មណ៍សិវកៃវល្យ ដែលមាននាទីរៀបចំពិធីសម្រាប់ព្រះមហាក្សត្រតាមបវេណីព្រាហ្មណ៍នោះ ឱ្យទៅជាបព្វជិតកំពូលរបស់ព្រះអង្គវិញ។ ភស្តុតាងមួយទៀតដែលបង្ហាញឱ្យកាន់តែច្បាស់ថា ព្រះអង្គជាពុទ្ធសាសនិកនោះគឺព្រះអង្គមានមរណៈនាមថានិវ៌ាបទ។

**-រាជ្យព្រះបាទជ័យវរ្ម័នទី៧**

ព្រះមហាវីរក្សត្រដ៏ឆ្នើមបំផុតរបស់ខ្មែរនាសម័យអង្គរ គឺព្រះបាទជ័យវរ្ម័នទី៧ដែលជាស្ថាបនិកទី៣នៃទីក្រុងអង្គរ សំណង់ប្រាសាទជាច្រើនត្រូវបានសាងសង់នៅក្នុងរាជក្សត្រអង្គនេះ ដែលសំណង់ប្រាសាទទាំងនោះជាប្រភេទសំណង់បែបពុទ្ធសាសនា និង ខ្លះទៀតបង្ហាញពីការបញ្ចូលគ្នាទាំងពុទ្ធលក្ខណៈនិងព្រាហ្មណ៍លក្ខណៈទ្រង់គ្រងរាជ្យសម្បត្តិក្នុងឆ្នាំ(១១៨១-១២១៥) ដែលអ្នកប្រវត្តិវិទូ បានចាត់ទុកថាជាសម័យកាលមួយ



ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងឱវាទដល់សមណព្រាហ្មណ៍

ដែលកម្ពុជារុងរឿងជាទីបំផុត នៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ ក្រៅពីការរីកចម្រើនរុងរឿង ក្នុងផ្នែកសង្គមនយោបាយ ហើយវិស័យសាសនាក៏រីកចម្រើន ព្រមជាមួយនោះផងដែរ។ ព្រះអង្គបានលើកស្ទួយព្រះពុទ្ធសាសនាមហាយាន ឱ្យបានថ្កុំថ្កើងតែទោះជាយ៉ាងនេះក្តីព្រះអង្គក៏មិនដែលបំភ្លេចចោលព្រហ្មញ្ញសាសនានោះដែរ។ ព្រះអង្គបានបង្រួមសាសនាទាំងពីរចូលគ្នាតែមួយ ក្នុងបំណងដើម្បីលើកស្ទួយដល់ពុទ្ធសាសនាមហាយានដែលព្រះអង្គបានគោរពជាសាសនា របស់រដ្ឋនិងដើម្បីកុំឱ្យប្រជាពលរដ្ឋខ្មែរ ដែលនៅជាប់ជិតដាមជាមួយព្រហ្មញ្ញសាសនាមានការអាក់អន់ចិត្តផងដែរ។ភាពវៃឆ្លាតនេះបានធ្វើឱ្យមានការឯកភាពគ្នាក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្រោមការដឹកនាំរបស់ទ្រង់ និង ធ្វើឱ្យមានស្ថេរភាពនយោបាយក្នុងស្រុកផងដែរ។ លទ្ធិទេវរាជត្រូវបានប្រែក្លាយទៅជាពុទ្ធិរាជវិញ មានភស្តុតាង ដែលបង្ហាញថាពុទ្ធសាសនាមហាយានមានការរីកចម្រើនខ្លាំងនៅក្នុងសម័យនោះ ដូចជាសំណង់ប្រាសាទបែបពុទ្ធសាសនាជាច្រើនពាសពេញផ្ទៃប្រទេស..(**តនៅទំព័រទី២៤**)

# ក្រុមហ៊ុន Google កំពុងពិនិត្យទិន្នន័យផែនទីបន្ទាត់ព្រំដែនកម្ពុជាថៃឡើងវិញ

ក្រុមហ៊ុនGoogle ប្រចាំទីក្រុងហុងកុងបាន ឆ្លើយតបមករដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងសំណើរបស់កម្ពុជា អោយក្រុមហ៊ុនGoogleផ្លាស់ប្តូរទិន្នន័យផែនទីស្តីពីបន្ទាត់ព្រំដែន កម្ពុជាថៃ នៅតំបន់ប្រាសាទព្រះវិហារ។ ក្រុមហ៊ុនGoogleបាន បញ្ជាក់ថា គេនឹងបន្តពន្យល់លម្អិតបន្ថែមទៀតមករដ្ឋាភិបាលកម្ពុជា។

ក្រុមហ៊ុនGoogleបានសរសេរប្រាប់រដ្ឋាភិបាលកម្ពុជាថា ពួកគេកំពុងតែពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់ និងដោយប្រុងប្រយ័ត្នចំពោះសេចក្តីតវ៉ា របស់រដ្ឋាភិបាលកម្ពុជាទាក់ទងនឹងផែនទីបន្ទាត់ព្រំដែនប្រាសាទព្រះវិហារ។នេះជាការឆ្លើយតបរបស់ក្រុមហ៊ុនGoogle មករដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី៩កុម្ភៈម្សិលមិញ បន្ទាប់ពីក្រុមអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សរបស់ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជាបានសរសេរពន្យល់ក្រុមហ៊ុនGoogle កាលពីថ្ងៃទី ៥កុម្ភៈកន្លងទៅ។

អង្គភាពព័ត៌មាន និង ប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជា បានសរសេរលិខិតទៅក្រុមហ៊ុនGoogle នៅសហរដ្ឋអាមេរិកផងនិងនៅប្រទេសសិង្ហបុរីផង ដើម្បីប្រាប់ក្រុមហ៊ុនមួយនេះថា ពួកគេបានផ្សព្វផ្សាយផែនទីស្តីពីបន្ទាត់ព្រំដែនប្រាសាទព្រះវិហារមិនត្រឹមត្រូវ។ គេហទំព័រGoogle Earth បានផ្សាយផែនទីមួយដែលគេឃើញមានខ្សែបន្ទាត់ព្រំដែនពណ៌លឿងដែលគេអោយឈ្មោះថា ជាព្រំដែនអន្តរជាតិកម្ពុជាសៀមនេះ គេបានដាក់ប្រាសាទព្រះវិហាររបស់ខ្មែរជិតពាក់កណ្តាលអោយស្ថិតនៅក្នុងប្រទេសថៃ។

ភ្ជាប់ជាមួយលិខិតប្រតិកម្មរដ្ឋាភិបាលកម្ពុជាបានបង្ហាញផែនទីដងរែក ឧបសម្ព័ន្ធ១ ដែលថៃបានទទួលស្គាល់ជាផ្លូវការជាមួយបារាំង តាំង




Photo RFI

ពីឆ្នាំ ១៩០៨ និង ១៩០៩។ ផែនទីឧបសម្ព័ន្ធ១ គឺជាលទ្ធផល នៃការងារកំណត់ព្រំដែនកម្ពុជា - ថៃ ដែលបង្ហាញថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជា តាមរយៈការពន្យល់នេះរដ្ឋាភិបាលកម្ពុជាបានស្នើអោយក្រុមហ៊ុនGoogleផ្លាស់ប្តូរផែនទីចាស់ចោល ហើយដាក់ជំនួសវិញ នូវផែនទីឧបសម្ព័ន្ធ១វិញ។

នៅក្នុងលិខិត ឆ្លើយមករដ្ឋាភិបាលកម្ពុជា លោក Ross La Jeunesse ប្រធានកិច្ចការរដ្ឋាភិបាល និងនយោបាយសាធារណៈរបស់ក្រុមហ៊ុនGoogleប្រចាំអាស៊ីប៉ាស៊ីហ្វិកមិនបានបញ្ជាក់ថាGoogleនឹងដកចេញភ្លាមនូវទិន្នន័យផែនទីដែលកម្ពុជាបានប្រឆាំងនោះឡើយ។ប៉ុន្តែលោក Ross បានផ្តល់យោបល់ អោយរដ្ឋាភិបាលកម្ពុជាធ្វើលិខិតនិងផ្ញើទិន្នន័យផែនទីទៅក្រុមហ៊ុនTele Atlas ដោយផ្ទាល់ដែលនៅទីនោះហើយ ដែលគេអាចផ្លាស់ប្តូរទិន្នន័យផ្សព្វផ្សាយបាន។

ទោះយ៉ាងណាក៏ដោយ តំណាងក្រុមហ៊ុនGoogleបានបញ្ជាក់អោយដឹងថា គេនឹងសរសេរទាក់ទងមករដ្ឋាភិបាលកម្ពុជាថែមទៀត ជាមួយនឹងការពន្យល់ពិស្តារជាងនេះ ហើយថាពួកគេនៅរង់ចាំទទួលរាល់ព័ត៌មាន និងទិន្នន័យបន្ថែមដែលរដ្ឋាភិបាលកម្ពុជាចង់ផ្តល់ឲ្យពួកគេនោះ៕

**ប្រភពRFI**

# អន្តោប្រវេសន៍យួនខុសច្បាប់ជួលដីខ្មែរធ្វើអាជីវកម្ម

តាមប្រភពព័ត៌មាន ក្នុងស្រុកមួយនៅប្រទេសកម្ពុជាបានឲ្យដឹងថារយៈពេលចុងក្រោយនេះមានក្រុមអន្តោប្រវេសន៍ជនជាតិយួន ជាច្រើនគ្រួសារបានពពាក់ពពូនគ្នាទៅរស់នៅទាំងគឃ្លើនក្នុងទឹកដីប្រទេសកម្ពុជាដោយមិនមានទិដ្ឋាការឬវីសារអ្វីឡើយ ។

តាមការចុះផ្សាយរបស់ពត៌មានខាងលើបានឲ្យដឹងថា ថ្មីៗនេះជនជាតិយួនមានចំនួន២០គ្រួសារដែលមានសមាជិក ប្រមាណជិត ៦០នាក់ បាននាំគ្នាជួលដីរបស់ប្រជាពលរដ្ឋខ្មែរយើង សាងសង់ផ្ទះស្នាក់នៅតាមបណ្តោយព្រំដែន នៅភូមិកោះចំការ ឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត នៃព្រះរាជាណាចក្រកម្ពុជា ពួកគេបានប្រកបរបរចិញ្ចឹមបង្កាលើផ្ទៃដីលិចទឹកព្រៃស្នាច់ដោយមិនមានការក្រែងរអែងក្រុមអាជ្ញាធរដែនដីអ្វីទេ រីឯក្រុមអាជ្ញាធរក៏មិនខ្វីឈឺក្បាលពីការអនុវត្តច្បាប់អន្តោប្រវេសន៍នោះដែរ ។

យោងតាមការចុះផ្សាយពីកាសែតខាងលើបានឲ្យដឹងបន្ថែមទៀតថាពួកយួនអត់ច្បាប់ទាំង២០គ្រួសារនោះ ដែលធ្វើដំណើរចេញពីភាគខាងត្បូងនៃប្រទេសយៀកណាម។ ដោយពួកគេបានជួលដីក្រុមហ៊ុនចំនួន២ធ្វើការចិញ្ចឹមបង្ការយៈពេលយូរឆ្នាំមកហើយចំណែកកន្លែងចិញ្ចឹមបង្កាជាប់នឹងព្រំដែននោះមិនមានមនុស្សនិងអ្នកភូមិចេញចូលញឹកញាប់ពេកទេ ដោយសារភូមិសាស្រ្តនៅទីនោះ សំបូរព្រៃស្នាច់និងមានភក់ល្បាប់ពិបាកធ្វើដំណើរ។

ប្រជាពលរដ្ឋខ្មែរនៅក្នុងភូមិនោះ បានឲ្យដឹងថាសព្វថ្ងៃនេះ មានយួនអន្តោប្រវេសន៍ជាច្រើន កំពុងរស់នៅយ៉ាងសប្បាយនៅប្រទេសកម្ពុជា ជាពិសេសតាមបណ្តោយព្រំដែន យួនទាំងនោះមិនមានប៉ាស្ពរឬទិដ្ឋការចូលស្រុកខ្មែរស្របច្បាប់ឡើយ។

ទាក់ទិននឹងការលើកឡើងខាងលើ មន្រ្តីប៉ូលិសសក្តិ៣ម្នាក់ ប្រចាំការនៅប៉ុស្តិ៍ត្រួតពិនិត្យច្រកអន្តរជាតិ



ពួកអន្តោប្រវេសន៍យួនលក់បន្លែយ៉ាងសប្បាយនៅលើទឹកដីខ្មែរ

ព្រែកចាក ខេត្តកំពត បាននិយាយថា ពាក់ព័ន្ធរឿងប្រជាពលរដ្ឋយួនចូលទៅតាំងទីលំនៅ ក្នុងភូមិកោះចំការ ឃុំបឹងសាលាខាងត្បូងចំនួន២០គ្រួសារនេះ គឺមិនមានប៉ាស្ពឬទិដ្ឋការត្រឹមត្រូវឡើយ។ លោកប៉ូលិសសក្តិ៣រូបនោះ បានមានប្រសាសន៍បញ្ជាក់បន្ថែមទៀតថា បើតាមការស្រាវជ្រាវរបស់លោក មានតែបុរសជនជាតិយួនម្នាក់ ឈ្មោះតឿងប៉ុណ្ណោះ ដែលមានប្រើប្រាស់ប៉ាស្ពរស្របតាមច្បាប់ប្រទេសកម្ពុជា។

សូមជំរាបផងថា ការដែលពួកយួនមកជួលដីខ្មែរចិញ្ចឹមបង្កានោះ បើតាមប្រជាពលរដ្ឋឲ្យដឹងថា ជួលដីឲ្យយួនមួយហិកតាក្នុងមួយឆ្នាំ ត្រូវបង់ទៅម្ចាស់ដីប្រមាណ៥០០ដុល្លារ ហើយខ្មែរយើងនៅភូមិនោះធ្វើកម្មករស៊ីឈ្នួលឲ្យពួកអន្តោប្រវេសន៍យួន ដោយទៅកាប់ឆ្ការព្រៃស្នាច់ក្នុងមួយថ្ងៃបានលុយចំនួន៧ម៉ឺនដុងលុយយួន ប្រហែលជាស្មើ៤ដុល្លារប៉ុណ្ណោះ។

ហើយក្នុងពេលថ្មីៗនេះមានដំណឹងថាភាគីជនជាតិយួនទាំងអស់នោះ បានយកគ្រឿងចក្រទៅជីកដីជួលពីខ្មែរធ្វើអ៊ូបង្កាយ៉ាងសកម្ម ដោយមិនមានការភ្ញាក់ផ្អើលចំពោះអាជ្ញាធរដែនដីបន្តិចសោះឡើយ។ យើងបានដឹងថា ពួកយួនសព្វថ្ងៃនេះកំពុងរស់នៅស្រុកខ្មែរស្ទើរគ្រប់ខេត្តក្រុងទាំងអស់ដោយមិនមានក្តីព្រួយបារម្ភអ្វីទេ ព្រោះមានច្បាប់ការពារពួកគេ៕ **ដោយ កូនខ្មែរ**

# ព្រះរាជដំណើរទស្សនកិច្ចលាក់លៀមរបស់សម្ដេចសង្ឃពុទ្ធសាសនា ដាឡៃ ឡាម៉ា នៅសេតវិមាន




សម្ដេចសង្ឃទីបេ ដាឡៃ ឡាម៉ា នៅទីក្រុងវ៉ាស៊ីងតោន ថ្ងៃទី១៧ កុម្ភៈ ២០១០

លោកប្រធានាធិបតីអាមេរិកាំង បារ៉ាក អូបាម៉ា ទទួលឱ្យចូលសន្ទនាជាឯកជន ដោយគ្មានការអនុញ្ញាតឱ្យមានកាមេរ៉ាចូលមកថតអ្វីសោះឡើយ សម្ដេចសង្ឃ ដាឡៃ ឡាម៉ា នៅថ្ងៃព្រហស្បតិ៍១៨កុម្ភៈនេះ នៅសេតវិមាន ប៉ុន្តែនៅតែបណ្ដាលឱ្យប៉េកាំងខឹងសម្បាដដែល ប្រទេសចិនបានចោទមគ្គុទ្ទេសក៍ទីបេនិរទេសថាជាអ្នកដឹកនាំចលនាទាមទារផ្ដាច់ទឹកដី និងបានព្រមានប្រាប់ជាមុនថា ជំនួបបែបនេះនឹងមានផលប៉ះពាល់ដ៏អាក្រក់ទៅលើទំនាក់ទំនងតានតឹងរួចស្រេចទៅហើយ រវាងប៉េកាំងនិងវ៉ាស៊ិនតោន។

នៅរដូវក្ដៅឆ្នាំមុន លោក បារ៉ាក អូបាម៉ាបានលើកពេលនៃជំនួប ដែលគាត់ត្រូវមានជាមួយសម្ដេចសង្ឃពុទ្ធសាសនាទីបេ ដាឡៃ ឡាម៉ា នៅឱកាសព្រះរាជដំណើរឆ្លងកាត់របស់ព្រះអង្គនៅរដ្ឋធានីវ៉ាស៊ិនតោន ។ ដោយទើបតែបានចូលមកកាន់សេតវិមាន បានតែប៉ុន្មានខែលោកបារ៉ាក អូបាម៉ាចង់បានការចេញដំណើរដ៏ល្អជាមួយប្រទេសចិនដែលគាត់ប្រាថ្នាចង់ធ្វើសហប្រតិបត្តិការស្ដីពីសំណុំរឿងដូចយ៉ាងកូរ៉េខាងជើង ការប្រែប្រួលនៃអាកាសធាតុវិបត្តិហិរញ្ញវត្ថុនិងអៀរ៉ង់។

សេចក្ដីសំរេចចិត្តរបស់គាត់កាលណោះ បានទទួលរងការរិះគន់ខ្លាំងណាស់ ទាំងពីខាងពួកអ្នកសាធារណរដ្ឋទាំងពីខាងអង្គការការពារសិទ្ធិមនុស្ស ។នៅឆ្នាំនេះ គាត់បានសំរេចចិត្តទទួលខ្លួនខុស ប៉ុន្តែដោយហេតុតែថ្នាក់ដឹកនាំចិនមានក្ដីទោមនស្ស ជាខ្លាំងណាស់រួចស្រេចទៅ ហើយអំពីសេចក្ដីសំរេចចិត្តរបស់វ៉ាស៊ិនតោនលក់អាវុធឱ្យតៃវ៉ាន់ ថ្លៃជាង ៦០០០ លានដុល្លារលោកប្រធានាធិបតីអូបាម៉ាបានរៀបចំជំនួបតាមរបៀបមួយដើម្បីលើកកិត្តិយសដល់មគ្គុទ្ទេសក៍ទីបេផង ដោយពុំធ្វើឱ្យប៉េកាំងអាក់អន់ស្រពន់ចិត្តហួសហេតុផង ។ដូច្នេះ ទស្សនកិច្ចនេះមានលក្ខណៈលាក់លៀមតាមលទ្ធភាពអាចធ្វើទៅបាន។លោកបារ៉ាក អូបាម៉ានឹងពុំបង្ហាញខ្លួនជាសាធារណៈ នៅក្បែរសម្ដេចសង្ឃ ដាឡៃ ឡាម៉ាដូចលោក George Bush ដែលនៅឆ្នាំ២០០៧ បានប្រគល់មេដាយមាសនៃរដ្ឋសភាអាមេរិកាំងជូនទៅសម្ដេចសង្ឃ ដាឡៃ ឡាម៉ានោះឡើយ។លោកអូបាម៉ាក៏នឹងពុំទទួលសម្ដេចសង្ឃ នៅក្នុងបន្ទប់លំនៅឯកជនដូចលោកប៊ីលគ្លីនតុននោះទេ។ ជំនួបនឹងប្រព្រឹត្តទៅនៅសាលផែនទីWest Wing ពុំមែននៅការិយាល័យមូលទ្រវែងក្នុងសេតវិមាននោះឡើយ។ ដើម្បីកុំឱ្យប៉េកាំងអាក់អន់ចិត្ត សម្ដេចសង្ឃដាឡៃ ឡាម៉ាត្រូវយាងចូលតាមទ្វារតូចនិងបំពេញទស្សនកិច្ចរបៀបឆក់កណ្ដៀត។

ទោះបីសម្ដេចសង្ឃដាឡៃ ឡាម៉ាត្រូវយាងចូលតាមទ្វារតូចក្ដី តែមិនអាចធ្វើឲ្យប្រទេសមហាអំណាចមួយនេះស្ងប់រម្ងាប់ចិត្តបានទេ គឺចិននៅតែរក្សាគោលនយោបាយមិនគាំទ្រព្រះរាជដំណើរទស្សនកិច្ចនេះឡើយ នឹងមានការខឹងសម្បារជាខ្លាំង ចំពោះសហរដ្ឋអាមេរិក ។ ចិននឹងមានផែនការសងសឹកវិញ ប្រហែលជាចាត់វិធានការសេដ្ឋកិច្ចនិងវិស័យពាណិជ្ជកម្ម ដាក់ទណ្ឌកម្មមកលើសហរដ្ឋអាមេរិកនាពេលខាងមុខនេះឯង។

**ប្រភព RFI**

# ប្រវត្តិសង្ខេបព្រះភិរម្យភាសាក្រមង៉ុយ

អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរក្រមង៉ុយ ដែលខ្មែរគ្រប់រូបទទួលស្គាល់ថា ជាអ្នកបង្កើតច្បាប់ប្រៀនប្រដៅដាស់តឿនដល់កូនខ្មែរនិងបង្កើតវោហារស័ព្ទខ្មែរ។គាត់កើតនៅឆ្នាំ១៨៦៥ ឃុំកំបូល ស្រុកភ្នំពេញ ដោយសព្វថ្ងៃហៅថាស្រុក អង្គស្នួល ក្នុងខេត្តកណ្តាល មាននាមដើម អ៊ុក អ៊ូ ប៉ុន្តែមាតាបិតាលោកហៅក្រៅថាង៉ុយៗ ជាប់នាមនេះរហូតមក ហើយបានទទួលអនិច្ចកម្មទៅវិញក្នុងឆ្នាំ ១៩៣៩ ជន្មាយុ៧១ឆ្នាំ។

បិតាលោកនាម អ៊ុក ធ្វើមេឃុំ នៅឃុំកំបូល មានគោរម្យងារថា ចៅពញាធម្មធារា ហើយឯមាតាលោកជាកូនរបស់ពញាម៉ុក មេឃុំស្ពានថ្ម ស្រុក ខេត្តជាមួយគ្នាដែលមាតាបិតាត្រូវបងប្អូនជីទួតមួយគ្នា។

កាលពីកុមារ អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរក្រមង៉ុយ បានទៅសំណាក់រៀននៅជាមួយចៅអធិការវត្ត អង្គបឹងចកដែលជាស្រុកកំណើតរបស់លោកផ្ទាល់ ដោយគាត់ជាក្មេងឧស្សាហ៍រៀនសូត្រ បានបួសជាសាមណេរ ចេះធម៌អាថ៌ជ្រៅជ្រះ ហើយកាលបើពេញវ័យ២១ឆ្នាំសាមណេរ ក៏បំពេញឧបសម្បទាជាភិក្ខុ ដែលបានសិក្សាធម៌អាថ៌ស្វះស្វែងរៀនប្រែព្រះគម្ពីរត្រៃយបិដកដំបូង ក្នុងសំណាក់លោកគ្រូអាចារ្យទិត្យគង់វត្តបឹងចក ភូមិបែកស្គរ ឃុំបែកចាន ស្រុកភ្នំពេញ ខេត្តកណ្តាល។ បន្ទាប់ពីប្រែព្រះត្រៃយបិដក ភិក្ខុ ង៉ុយ ស្វែងរៀនឧបស្សនាកម្មដ្ឋានក្នុងសំណាក់ព្រះអាចារ្យជាច្រើនកន្លែងទៀត។

ក្រោយពីបានចាកសិក្ខាបទមកជាគ្រហស្ថលោក បានរៀបអាពាហ៍ពិពាហ៍នៅឃុំបែកចាន ស្រុកភ្នំពេញ



ព្រះភិរម្យភាសាក្រមង៉ុយ

ហើយប្រកបរបរអ្នកស្រែជាធម្មតាក្នុងស្រុកនោះឯង។ លោកមានកូន៦នាក់ឈ្មោះ អាចារ្យចុងដែលជាកវីមានឈ្មោះល្បីខាងសំនួនវោហារបានទទួលអនិកម្ម ក្នុងគុកនយោបាយនៅឆ្នាំ១៩៥៥ពេលបោះឆ្នោតគណបក្សប្រជាធិតេយ្យប្រកួតប្រជែងនិងបក្សសង្គមរាស្ត្រនិយម។

ក្នុងការរស់នៅជាកសិករ តាង៉ុយ មានប្រជាប្រិយភាពខ្លាំងខាងវោហារនិងល្បិចលើកកំណាព្យភ្លាមៗមកច្រៀងឡើង និងសំនៀងសាដៀវយ៉ាងពិរោះ ព្រមទាំងចំណេះខាងធម៌អាថ៌យ៉ាងខ្ពង់ខ្ពស់ ដែលធ្វើឱ្យកសិករឯទៀតរាប់អានស្រឡាញ់ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុកហើយអ្នកស្រុកហៅលោកថា ភិរម្យ ង៉ុយ។ បន្ទាប់មករដ្ឋអំណាចបានតាំងលោកជា( ក្រម ) គឺជាភារៈជនដែលធ្វើទំនាក់ទំនងទាក់ទងរវាងរដ្ឋបាល និងប្រជាជនក្នុងឃុំ។

ពេលរដូវរំហើយ ក្រោយពីកិច្ចការច្រូតកាត់អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរក្រមង៉ុយ.....(**តទៅទំព័រទី ២២**)

(តមកពីទំព័រទី៣)
បកស្រាយឬវែកញែកទេ គឺទុកឲ្យសង្គមសង្ឃជាអ្នកដោះស្រាយតាមវិន័យចុះ គ្រាន់តែយើងមានការសោកស្តាយហើយសង្ឃឹមថា កំហុសទាំងឡាយដែលបុគ្គលណាបានធ្វើមកនោះ មិនអាចមានលក្ខណៈនាំបង្កើតភាពអន្តរាយធំធេងពេកទេ។ ហើយអ្នកដែលប្រព្រឹត្តខុសត្រូវទទួលសារភាពចំពោះមុខច្បាប់ ពីព្រោះថាកំហុសដែលមិនបានសារភាពនោះ គឺជាកំហុសត្រួតពីរដងដែលរុញច្រានស្ថានការណ៍ឲ្យកាន់តែធ្ងន់ធ្ងរ ហើយក្នុងរឿងនេះគ្មានអ្នកណាដឹងនូវកំហុសនោះធំរឺតូចជាងអ្នកដែលបានប្រព្រឹត្តខ្លួនឯងឡើយ។

«Anybody makes mistake, but make sure that the mistake doesn't cost too much and the same mistake won't be repeated».

វិលមកពុទ្ធបរិស័ទ និងគណៈកម្មការវត្តវិញ វិបត្តិកាន់តែលេចឮមានច្រើន រហូតមានការប្តឹងផ្តល់គ្នាអូសវែងអន្លាយ នាំឲ្យបង់ខាតលុយកាក់ជាថវិការវត្តដ៏ច្រើនសន្ធឹកសន្ធាប់ ជាបច្ច័យដែលពុទ្ធសាសនិកជនបានធ្វើការបូជាដោយសទ្ធាជ្រះថ្លាបំផុត ចំពោះពុទ្ធសាសនា។ អស់ថវិការវត្តហើយ ក៏រកដំណោះស្រាយចេញមិនរួច គឺមានតែធ្វើឲ្យបញ្ហានោះស្មុគស្មាញខ្លាំងឡើងទៅទៀត។ព្រឹត្តិការណ៍នេះ បានកែប្រែទិដ្ឋភាពវត្តអារាមខ្លះដែលធ្លាប់តែជាទីស្ងប់រម្ងាប់និងបូជណីយដ្ឋានបង្កើតទឹកចិត្តជ្រះថ្លា មេត្តា ករុណា សច្ចៈ ខន្តីផងនោះ ហើយក៏ជាទីកន្លែងសម្រាប់ផ្សះផ្សារកសាមគ្គី សមភាព អ្នកតូចដូចជាអ្នកធំ អ្នកក្រក៏ដូចជាអ្នកមាននោះ ឲ្យទៅជាទីលានឈ្លោះប្រកែកតតាំងយកឈ្នះយកចាញ់ទៅវិញ។ស្ថានភាពបែបនេះ មិនគ្រាន់តែនាំឲ្យពុទ្ធបរិស័ទមានការអស់ជំនឿឬនឿយណាយមិនចង់ទៅវត្តទៀតប៉ុណ្ណោះ ប៉ុន្តែជាការគួរឲ្យខ្មាសអៀន ដោយបានទម្លាក់តម្លៃព្រះពុទ្ធសាសនាឲ្យធ្លាក់ទាបបំផុត នៅចំពោះមុខសាសនាដទៃទៀត។ ការយកឈ្នះយកចាញ់គ្នាតាមផ្លូវច្បាប់ បានបង្ហាញថា គ្មានអ្នកណាម្នាក់យល់ព្រមទទួលថាជាកំហុសរបស់ខ្លួនទេ ហើយអ្នកបានធ្វើខុសដែលមិនទទួលទោស អាចជាអ្នកធ្វើខុសច្រើនពេករហូតដល់លែងដឹងថាអ្វីជាខុស អ្វីជាត្រូវ។ បើតាមយល់ឃើញរបស់ខ្ញុំមុតបន្ទាត្រូវយកបន្លាដោះយ៉ាងណាមិញដោយសំអាងលើច្បាប់ប្តឹងផ្តល់ ក៏ឃើញថាបានជាលទ្ធផលត្រឹមតែការខាតបង់ពេលវេលានិងធនធានច្រើនលើសលប់នៅតែរកដំណោះស្រាយមិនចេញ ដូច្នេះបើប្រាកដជាអ្នកគោរពស្រឡាញ់ពុទ្ធសាសនាវត្តអារាមមែន ទំនាស់ក្នុងព្រះពុទ្ធសាសនាគួរតែវិលមកដោះស្រាយ តាមបែបឪវាទព្រះពុទ្ធ គឺការលះបង់មានះរឹងត្អឹងនិងគំនុំគុំគួន ការចាញ់ឈ្នះ ព្រមទាំងលះបង់អាត្មានិយម ឈប់និយាយវាយប្រហារគ្នាដោយពាក្យសម្តី ត្រូវស្វែងយល់ឲ្យបានច្រើនបំផុតអំពីឪវាទប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គដើម្បីទុកជាពន្លឺសម្រាប់ឈោងចាប់ការដោះស្រាយ ទៅរកសាមគ្គីភាពឡើងវិញ។

គ្មានបញ្ហាណាដែលដោះស្រាយមិនបាននោះទេ ប៉ុន្តែភាគីពាក់ព័ន្ធត្រូវមានឆន្ទៈក្នុងការបកស្រាយហើយធ្វើសម្បទានឲ្យបានច្រើនបំផុត។ សុភាសិតបុរាណខ្មែរបានពោលថា *«នៅផ្ទះម្តាយទីទៃ នៅព្រៃម្តាយជាមួយ»*។ យើងទាំងអស់គ្នាដែលឃ្លាតចាកពីមាតុភូមិកំណើត ទុកដូចជាបានឃ្លាតឆ្ងាយពីផ្ទះទាំងអស់គ្នាគួរណាស់តែមានការយោគយល់អត់ឱន អធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក កុំចាំតែមើលបំណាំនឹងចាប់កំហុសគ្នាហើយគួរបង្វែរចិត្តគំនិតមករួបរួមកម្លាំងសាមគ្គីដើម្បីកសាងវត្តអារាមពីទិដ្ឋភាពសៅហ្មង ឲ្យទៅជាទីកន្លែងមានសច្ចៈ ខន្តី ស្ងប់រម្ងាប់ ទាំងផ្លូវកាយ-ផ្លូវចិត្តទៅវិញ នេះប្រហែលជាជំរើសមួយដែលត្រឹមត្រូវបំផុតដែលនៅក្នុងក្របខ័ណ្ឌនៃឪវាទប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ៕

**ដោយ ព្រឹទ្ធាចារ្យ នឹង សិន**

(តមកពីទំព័រទី១២)

កម្រិតទាបនោះគឺមានយុវវ័យមួយចំនួនដែលបានតាមដានពីការស្រុតចុះនូវសីលធម៌ យុវជននោះ ក៏បានសំដែងភាពមិនពេញចិត្តអំពីបញ្ហានេះដែរ។

យុវជនមួយរូបឈ្មោះ សុខ ដារា រៀននៅវិទ្យាល័យកំពង់កន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានបញ្ជាក់ប្រាប់ អំពីការសង្កេតឃើញរបស់គេយ៉ាងដូច្នេះ ៖ *«ខ្ញុំ មើលស្ថានភាពរាល់ថ្ងៃនៅក្នុងភូមិហ្នឹង គឺសំបូរក្មេងទំនើងពេលមានបុណ្យទានមានរាំវ៉ៃកអីអ៊ីចឹង គ្រាន់តែឃើញមុខគ្នា ប៉ះគ្នាបន្តិចវ៉ៃគ្នាប្រាវ អ៊ីចឹងវាប៉ះពាល់ មានរបួសអីក្នុងស្រុកក្នុងភូមិ»*។

ព្រះតេជព្រះគុណ ភួង សុភឿន ព្រះចៅអធិការវត្តបន្ទាយរការ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងជាមន្ត្រីសង្ឃប្រចាំស្រុកភ្នំស្រួច បានមានព្រះថេរដីកាថា សព្វថ្ងៃនេះសីលធម៌រស់នៅក្នុងសង្គមខ្មែរគឺសង្កេតឃើញហាក់មានភាព ច្របូកច្របល់ខ្លះ គឺហាក់ស្របទៅនឹងសុភាសិតបុរាណខ្មែរមួយបានចែងថា៖

*«សត្វបង្គួយទៅជាសត្វជាស មាសទៅជាសំណ ភ្នំអត់ថ្ម ស្រីល្អអត់ប្ដី។ បង្គួយទៅជាសហ្នឹងយ៉ាងម៉េច? សម័យបច្ចុប្បន្នហ្នឹងប្រុសទៅជាស្រី ស្រីទៅជាប្រុស ប្រុសទៅជាសក់វែងចោះត្រចៀកពាក់មួយចំហៀង ពីរបីអ៊ីចឹងទៅ ហើយស្រីៗក៏អ៊ីចឹងដែរ ពីមុនស្លៀកសំពត់ ឥឡូវទៅជាស្លៀកខ្លី។ មាសក្លាយទៅសំណ កូនប្រុសស្រីអត់ស្ដាប់ដំបូន្មានឪពុកម្ដាយ អត់ខ្លាចឪពុកម្ដាយ។ ភ្នំអត់ថ្ម គឺព្រះសង្ឃហ្នឹងអត់មានសីលធម៌ អត់សិក្សា។ ស្រីល្អអត់ប្ដី សំដៅដល់មនុស្សទូទៅអត់មានសីល៥ កាលណាអត់សីល៥ ហើយមានស្អីទៀតនៅក្នុងខ្លួន។ ត្រង់កន្លែងហ្នឹងហើយដែលថា សីលធម៌ធ្លាក់ចុះ»*។

ការបង្ហាញប្រាប់ពីសីលធម៌ របស់យុវវ័យសព្វថ្ងៃធ្លាក់ចុះនោះ ត្រូវបានគេកត់សម្គាល់ឃើញថា ដោយសារកត្តាបីយ៉ាងគឺ ខ្វះការយកចិត្តទុកដាក់ពីសង្គមគ្រួសារពីសង្គមសាលារៀននិងសង្គមដែលនៅជុំវិញ។

ស្ត្រីចាស់ទុំខ្មែរមួយរូបនៅទីក្រុងភ្នំពេញ ឈ្មោះ គឹម ស៊ីមឿន បានមានប្រសាសន៍បញ្ជាក់ពីបញ្ហានេះបន្ថែមយ៉ាងដូច្នេះ ៖ *«មាតាបិតាខ្លះគ្នាក្រ ដល់ចេញទៅរកស៊ីអ៊ីចឹងទៅ កូនហ្នឹងទៅរៀនមិនទៅរៀនអី ទៅសេពគប់នរណាក្ដីក៏អត់ដឹងទាំងអស់។មួយទៀតម្ដាយឪពុកទម្រើសកូន ហើយឥឡូវសម្ភារៈនិយមច្រើន វាចង់ទារលុយប៉ុន្មានក៏ឲ្យកូនចេះតែទារបានមិនដែលជួបការលំបាក វាចេះតែចាយផ្ដេសផ្ដាសមានមិត្តភក្ដិធ្វើអាក្រក់។ អ៊ីចឹងបានថា កូនអ្នកមានក៏ពិបាក កូនអ្នកក្រក៏ពិបាក ដោយសារអី? ដោយសារខ្វះការអប់រំ»*។

ព្រះតេជព្រះគុណ ភួង សុភឿន ដែលជាប្រធានថេរសភាស្រុកភ្នំស្រួចដែរនោះ បានបញ្ជាក់ប្រាប់ទៀតថា ដើម្បីជួយលើកដម្កើងនូវសីលធម៌ក្នុងសង្គមខ្មែរឲ្យបានថ្កុំថ្កើងឡើងវិញនោះ ចាំបាច់គឺមនុស្សខ្មែរគ្រប់រូបមិនសំដៅតែយុវវ័យទេ ត្រូវនាំគ្នារក្សាឲ្យបានខ្ជាប់ខ្ជួននូវសីលទាំងប្រាំ ពីព្រោះសីលប្រាំ គឺជាសីលធម៌រស់នៅរបស់មនុស្សទូទៅ។

ព្រះតេជព្រះគុណ ភួង សុភឿន មានព្រះថេរដីកាដូច្នេះ ៖ *«សំដៅដល់មនុស្សដែលមានគុណធម៌នៅក្នុងខ្លួន ទី១មិនសម្លាប់ មិនប៉ះពាល់ជីវិតអ្នកដទៃ ទី២មិនទៅលួចប្លន់ឆក់ទ្រព្យសម្បត្តិអ្នកដទៃ ទី៣មិនប្រព្រឹត្តិខុសនៅក្នុងព្រហ្មចរិយាធម៌ សំដៅដល់ប្រពន្ធកូនអ្នកដទៃ ឬប្រព្រឹត្តខុសចំពោះកូនរបស់ខ្លួនឯងអីជាដើមហ្នឹង ជារឿងមួយសំខាន់ណាស់ក្នុងសីលធម៌ទី៣ ។សីលធម៌ទី៤ មិននិយាយកុហកភូតភរ បោកប្រាស់ ហើយទី៥សំដៅដល់គ្រឿងសុរា គ្រឿងញៀន ឬថ្នាំដែលធ្វើមនុស្សយើងបាត់នូវឧត្តមគតិល្អ។ បើមនុស្សមានធម៌ទាំង៥នៅក្នុងខ្លួនហ្នឹង គឺឧត្តមគតិតម្លៃគ្មានអ្វីប្រៀបផ្ទឹមបានទេ»*។.................. ***(តទៅទំព័រទី២២)***

# ក្រសួងមហាផ្ទៃសារភាពថា ក្រុមអាជ្ញាធរត្រូវការលុយសំរាប់បញ្ចប់នីតិវិធី ច្បាប់ផ្តល់ឯកសារពាក់ព័ន្ធដល់ក្រុមជនភៀសខ្លួនខ្មែរក្រោម

ក្រុមជនភៀសខ្លួនខ្មែរកម្ពុជាក្រោម ចំនួន ១៩ នាក់ ដែលកំពុងលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញ បន្ទាប់ពីត្រូវបានក្រុមតម្រួតថៃចាប់បញ្ជូនទៅកាន់ប្រទេសកម្ពុជានៅថ្ងៃ ទី ៥ ធ្នូ ឆ្នាំ២០០៩ បាននិយាយត្អូញត្អែរថា ពួកគេគ្មានថវិកាសំរាប់សូកប៉ាន់ ដល់ក្រុមអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានឯកសារពាក់ព័ន្ធស្របច្បាប់ទេ។

បន្ទាប់ពីការថ្លែងរបស់លោក ខៀវ សុភ័គ អ្នក អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានឲ្យបណ្តាញសារព័ត៌មានក្នុងស្រុកបានដឹងថា គេបានអនុវត្តជាទូទៅ តម្រូវការលុយកាក់ខ្លះ ៗ សំរាប់ឯកសារពាក់ព័ន្ធស្របច្បាប់ ។ លោក ខៀវ សុភ័គ្គ បានឲ្យកាសែតភ្នំពេញប៉ុស្ត៍ដែលផ្សាយជាភាសាអង់គ្លេសដឹងថា វាជារឿងធម្មតាដែលក្រុមអាជ្ញាធរត្រូវការថវិកាបន្តិចបន្តួចសំរាប់ទិញបារីដក់ ឬអាហារពេលព្រឹក។ នៅប្រទេសលោកខាងលិចរីសហរដ្ឋអាមេរិក ប្រសិនបើយើងចង់ទៅមន្ទីរពេទ្យ គឺយើងត្រូវចំណាយថវិកាជាច្រើន។

ពីការថ្លែងជាសាធារណៈនេះ ក្រុមជនភៀសខ្លួនខ្មែរកម្ពុជាក្រោម បានឲ្យដឹងយ៉ាងច្បាស់ថាពួកគេនឹងមិនអាចទទួលបានសៀវភៅគ្រួសារសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ និងឯកសារពាក់ព័ន្ធផ្សេងៗ ឡើយ កុំថាឡើយដីធ្លីកសិកម្មដែលពួកគេប្រាថ្នាចង់បានដើម្បីប្រកបរបបចិញ្ចឹមជីវិតស្របពេល ដែលរដ្ឋាបាលកម្ពុជាបានប្រកាសអនុញ្ញាតនិងទទួលស្គាល់ពួកគេជាពលរដ្ឋខ្មែរ។លោកថាច់ សុង តំណាងជនភៀសខ្លួនខ្មែរក្រោម ។ ដែលកំពុងលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញ បានត្អូញត្អែរប្រាប់វិទ្យុសំឡេងកម្ពុជាក្រោមថា ក្រោយពេលពួកគេសំរេចចិត្តរត់ចេញពីវៀតណាមខាងត្បូង ដែលជាអតីតដែនដីកម្ពុជាក្រោម ពួកគេគ្មានទីពឹង គ្មានកន្លែងស្នាក់អាស្រ័យ ហើយថែមទាំងទទួលរងការគំរាមតាមធ្វើបាបទៀតផង។ លោក ថាច់ សុង បានអះអាងថា



ជនភៀសខ្លួនខ្មែរក្រោមកំពុងរស់នៅប្រទេសកម្ពុជា/photo KI

លោកមិនអាចនឹងវិលត្រឡប់ទៅកាន់ទឹកដីកំណើតកម្ពុជាក្រោមវិញបានទេ ព្រោះអាជ្ញាធរយួនកំពុងតាមចាប់ខ្លួន ទាំងនេះក៏ដោយសារបងប្អូនខ្មែរក្រោមដទៃបាននាំគ្នាបះបោរប្រឆាំងនឹងរដ្ឋាភិបាលក្រុងហាណូយ។ រឿងរំលោភសិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិជំនឿសាសនា និងសិទ្ធិកាន់កាប់ដីធ្លី។ លោកថាច់ សួង បានប្រាប់វិទ្យុសំឡេងកម្ពុជាក្រោមឲ្យដឹងទៀតថាគ្រួសារលោកក៏ដូចជាបងប្អូនជនភៀសខ្លួនដទៃផ្សេងទៀត គឺគ្មានបងប្អូននិងញាតិផៅនៅក្នុងប្រទេសកម្ពុជាឡើយ។តំណាងជនភៀសខ្លួនរូបនេះបានបន្តថា ពួកគេគ្មានសមត្ថភាពរកលុយសំរាប់ការបង់ជូនទៅអាជ្ញាធរនោះទេព្រោះពួកគេគ្មានលិខិតទទួលស្គាល់ជាលាយលក្សអក្សរ និងឯកសារពាក់ព័ន្ធដែលបញ្ជាក់ថា ពួកគេជាពលរដ្ឋខ្មែរស្របច្បាប់ ដូច្នេះពួកគេមិនអាចទៅស៊ីឈ្នួលគេបានឡើយ។ លោកថាច់ សួង បញ្ជាក់ថា លោកជឿជាក់ថា ពួកអាជ្ញាធរនឹងមិនធ្វើឯកសារពាក់ព័ន្ធជូនពួកគេទេ ពីព្រោះពួកគេគ្មានលុយបង់ឲ្យអាជ្ញាធរមានសមត្ថកិច្ច ។

រីឯស្ត្រីជនភៀសខ្លួនម្នាក់ទៀតឈ្មោះដុំកក៏បានឲ្យដឹងដែរថា សព្វថ្ងៃនាងគ្មានថវិកាសំរាប់ទទួលទានអាហារផងកុំថាឡើយថវិកាសំរាប់ (**តទៅទំព័រទី២៨**)

## រដ្ឋាភិបាលកម្ពុជា បានយល់ព្រមឱ្យខ្មែរកម្ពុជាក្រោមផ្សព្វផ្សាយពត៌មាន តាមវិទ្យុជាតិ



ឯកឧត្តម ខៀវ កាញ្ញារិទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

កាលពីថ្ងៃអង្គារ ឆ្នាំ២០១០កន្លងទៅនេះ លោក ខៀវ កាញ្ញារិទ្ធ រដ្ឋមន្ត្រីក្រសួងពត៌មានបានយល់ព្រម ឱ្យអង្គការសមាគមខ្មែរកម្ពុជាក្រោមផ្សព្វផ្សាយព័ត៌មាន អំពីវប្បធម៌ និង ប្រវត្តិសាស្ត្រខ្មែរកម្ពុជាក្រោមនៅតាម ស្ថានីយវិទ្យុជាតិចំនួន៧កន្លែង នៅក្នុងទីក្រុងភ្នំពេញ និងនៅតាមខេត្តមួយចំនួន។

លោករដ្ឋមន្ត្រី បានស្នើឲ្យអង្គការសមាគមទាំងនោះ ធ្វើការពិភាក្សានិងជជែកជាមួយស្ថានីយវិទ្យុទាំង ៧ខេត្តក្រុងអំពីលក្ខណៈបច្ចេកទេស និងការផលិតកម្មវិធីផ្សាយ។ គោលបំណងនៃការផ្សព្វផ្សាយនោះគឺផ្តោតទៅលើវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី អក្សរសាស្ត្រ ភាសា និងពង្សាតាខ្មែរកម្ពុជាក្រោមជាដើម។ លោក អាងច័ន្ទរិទ្ធអតីតសកម្មជនសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម បានសំដែងការត្រេកអរចំពោះការយល់ព្រមនេះ លោកមានប្រសាសន៍ថា វាជាចំនុចវិជ្ជមាន ដែលរដ្ឋាភិបាល ទទួលយកសំណើ ហើយអនុញ្ញាតឲ្យខ្មែរក្រោមធ្វើការផ្សព្វផ្សយតាមរលកជាតុអាកាសរបស់ជាតិដើម្បីបំបាត់ នូវការរើសអើង និង ការរំលោភសិទ្ធិមនុស្សនានាលើពួកគេ។ លោក ថាច់ សេដ្ឋា បានបញ្ជាក់បន្ថែមថា យើងមានការព្រួយបារម្ភ នៅពេលដែលយើងពិភាក្សាគ្នាវាអាចប៉ះពាល់ ពីព្រោះកាលណាការផ្សាយរឿងខ្មែរក្រោមតែងតែនិយាយ អំពីការតស៊ូ និងទុក្ខលំបាក ដូចជាបច្ចុប្បន្ននេះ អាជ្ញាធរវៀតណាមកំពុងតែហាមខ្មែរក្រោមមើលទូរទស្សន៍ស្តាប់វិទ្យុខ្មែរនិងរៀនអក្សរសាស្ត្រខ្មែរ។ លោក អ៊ំ សំអាត ប្រធានផ្នែកស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្ស Licadhoបានបញ្ជាក់ថាវាជាជំហ៊ានវិជ្ជមានមួយក្នុងការចូលរួមចំណែកនៅក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប៉ុន្តែយើងចង់បានការផ្សព្វផ្សាយនេះឱ្យបានទូលំទូលាយថែមទៀត។

សូមបញ្ជាក់ថា ប្រធានស្ថានីយវិទ្យុ FM ជាតិចំនួន៧ និងតំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម គ្រោងនឹងជួបពិភាក្សាគ្នានៅពេលខាងមុខនេះ៕

**ដោយ កន្ទរតោ ប្រភព VOK**

## គណៈប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម ជួបសំណេះសំណាលជាមួយ សម្តេចសង្ឃ ដាឡៃ ឡាម៉ា



គណៈប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម នៅរដ្ឋធានីវ៉ាស៊ីនតោន

កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០កន្លងទៅថ្មីៗនេះ គណៈប្រតិភូរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម មួយក្រុម ដឹកនាំដោយលោក ត្រឹង ម៉ានរិន អគ្គនាយកផែនការ លោក ត្រឹង យ៉ាប អគ្គនាយករដ្ឋបាល ព្រះតេជគុណ ធម្មោ ទ្រៀង អគ្គលេខាធិការ និងលោក ថាច់ លេន នី តំណាងយុវជនខ្មែរកម្ពុជាក្រោមបាននិមន្តនិង អញ្ជើញទៅចូលរួម ក្នុងពិធីប្រគេនរង្វាន់មាសប្រជាធិបតេយ្យ ដល់សម្តេចសង្ឃ ដាឡាយ ឡាម៉ា ជាអ្នកដឹកនាំកំពូលនៃជនជាតិទីបេ នៅបណ្តា... **(តទៅទំព័រទី២៩)**

**(តមកពីទំព័រទី៤)** បង្កើនមនសិការស្នេហារសម្បត្តិវប្បធម៌ជាតិ និងជំរុញទឹកចិត្តប្រជាជនឲ្យស្គាល់ពីស្នាដៃឯកនៃស្ថាបត្យកម្មខ្មែរ ដែលមានប្លង់ក្បាច់រចនាល្អឥតខ្ចោះផ្សារភ្ជាប់ជាមួយទេសភាពនិងបរិស្ថានជុំវិញប្រាសាទជាដើម។

សូមប្រជាពលរដ្ឋខ្មែរនៅគ្រប់មជ្ឈដ្ឋានទាំងអស់ មេត្តាពង្រឹងស្មារតីដើម្បីចូលរួមថែរក្សាមត៌កជាតិឲ្យបានគង់វង់ជាអមតៈ ជាពិសេសកំលាំងសាមគ្គីរបស់កងទ័ពកម្ពុជា សុខចិត្តបូជាកាយព្រួតដៃគ្នាការពារបូរណភាពទឹកដី មិនឲ្យបាត់បង់ជាដាច់ខាតទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ព្រោះប្រាសាទព្រះវិហារបានក្លាយទៅជាបេតិកភណ្ឌពិភពលោក ហើយក៏ជាសម្បត្តិរបស់មនុស្សជាតិផងដែរ៕

**ដោយ ស៊ឹម សុរិយា**

---

**(តមកពីទំព័រទី១៧)** តែងតែទេសនាប្រៀនប្រដៅ ច្រៀងកំណាព្យបន្ទរដោយសំនៀងសាដៀវដ៏ក្រលួចពីភូមិមួយទៅភូមិមួយ ដោយយំស្រណោះអាណិតខ្មែរគ្នាឯង ពីភាពខ្សត់ខ្សោយ ក្រីក្រ ល្ងង់ខ្លៅ ឈ្លោះគ្នាឯងបែកបាក់សាមគ្គី។ល ។ ផ្ទុយនឹងទម្ងន់ពន្ធដារនៃរដ្ឋអំណាចបារាំង ភាពហ៊ើសហួនឆ្លាតការកេងបន្លំរបស់ជនបរទេស មានចិនយួន ជាដើម។ សំនួរល្បើល្បាញពីកវីសិល្បករនេះ លេចឮដល់ទីក្រុង ហើយសម្តេចចក្រីបានហៅឱ្យទៅច្រៀងថ្វាយស្តេចស៊ីសុវត្ថិ ពេលនោះព្រះអង្គពេញព្រះទ័យបានឱ្យរង្វាន់ជាប្រាក់កាសនិងគោរម្យងារជា ព្រះភិរម្យភាសា។

សំនួរល្បើល្បាញតាង៉ុយនេះដឹងដល់លោកសឺ ដេស សមាជិកសាលាបារាំងចុងបូព៌ាប្រទេសនាំទៅជួបអ្នកស្រីស៊ុសានកាពេលេស នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពកំណាព្យ តា ង៉ុយ ជាកូនសៀវភៅប្អូន។ អ្នកស្រីកាពេលេស បានឱ្យកំរៃជាប្រាក់១រៀលជំនាន់នោះ។ ប្រាក់១រៀលតិចមែនពិត តែអំណោយនេះសឹងតែទុកជាកិច្ចប្រវត្តិសាស្ត្រ បង្ហាញឱ្យឃើញថា បារាំងទាំងអស់មិនមែនសុទ្ធតែអ្នកអាណានិគមមកជិះជាន់ខ្មែរ គឺមានអ្នកប្រាជ្ញខ្លះៗស្រឡាញ់រាប់អានវប្បធម៌ខ្មែរចង់រក្សាទុកជាស្នាដៃមនុស្សធម៌។ នៅពេលអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ ក្រម ង៉ុយទទួលអនិច្ចកម្មទៅ គាត់បានបន្សល់ស្នាដៃចុងក្រោយជាបណ្តាំក្រម ង៉ុយ បង្ហាញពីភាពល្ងង់ខ្លៅ និងការខ្ជិលច្រអូសនៃជនជាតិយើង នៅមុខភាពហ៊ើសហួនឆ្លាតកេងប្រវ័ញ្ចនៃជនបរទេសមាន ចិន យួនជាដើម។

ឯកសារស្រាវជ្រាវ

---

**(តមកពីទំព័រទី១៩)** អ្នកចាស់ទុំខ្មែរមួយចំនួនទាំងនៅទីក្រុងភ្នំពេញនិងតាមខេត្តនានា បានបញ្ជាក់ប្រាប់ដែរថា ការឲ្យរក្សាសីលប្រាំគឺជាការអប់រំសីលធម៌មួយយ៉ាងល្អប្រពៃហើយក្នុងនោះបើមានការជួយជ្រោមជ្រែងអប់រំបន្ថែមទៀតពីសំណាក់ឪពុក ម្តាយអាណាព្យាបាល គ្រូបង្រៀន ព្រះសង្ឃនិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដោយមិនមើលបំណាំគ្នានោះ គេរំពឹងថា យុវវ័យខ្មែរនឹងទទួលបាននូវការអប់រំសីលធម៌ល្អ។ អ្នកចាស់ទុំទាំងនោះបានបន្ថែមទៀតថា បើយុវជនយុវតីបានធ្វើតែអំពើល្អហើយនោះ គឺអាចជួយជំរុញឲ្យខ្លួនគេឲ្យក្លាយជាពលរដ្ឋល្អ ហើយនិងជួយកសាងសង្គមជាតិឲ្យមានការរីកចម្រើនផងដែរ៕

**ប្រភព RFA**

# សន្និសីទរបស់ អ.ស.ប.ប្រឆាំងនឹងការរើសអើងជនជាតិភាគតិចនៅកម្ពុជា



KKF ក្នុងកិច្ចប្រជុំជាមួយនឹងថ្នាក់ដឹកនាំ UNPO នៅអ៊ីតាលី

អង្គការសហប្រជាជាតិ (អ.ស.ប.) ផ្តោតការយកចិត្តទុកដាក់ប្រឆាំងនឹងការរើសអើង របស់ប្រទេសមួយចំនួន ចំពោះពលរដ្ឋដែលជាជនជាតិដើមភាគតិច ដែលក្នុងនោះមានកម្ពុជាផងដែរ។

គណៈកម្មាធិការCERDឬហៅថា គណៈកម្មាធិការផ្នែកប្រឆាំងនឹងការរើសអើងពូជសាសន៍ របស់អង្គការសហប្រជាជាតិបានបើកសន្និសីទ ក្នុងសប្តាហ៍នេះ នៅទីក្រុងហ្សឺណែវប្រទេសស្វ៊ីសដោយកោះហៅ តំណាងរដ្ឋាភិបាល នៃប្រទេសមួយចំនួនឲ្យមកឆ្លើយបំភ្លឺថា តើប្រទេសទាំងនោះ មានការរើសអើងលើជនជាតិដើមភាគតិចឬទេ? សម្រាប់កម្ពុជាគឺគេបានរៀបចំកិច្ចប្រជុំកាលពីថ្ងៃព្រហស្បតិ៍ ទី១៨ និងថ្ងៃសុក្រទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ដោយមានគណៈប្រតិភូមួយក្រុមនៃសហព័ន្ធខ្មែរកម្ពុជាក្រោមដឹកនាំដោយលោក ថាច់ ង៉ុក ថាច់ ទៅចូលរួម និងមានខ្មែរជាជនជាតិភាគតិច៣រូបមកពីខេត្តកំពង់ធំមណ្ឌលគិរីនិងរតនគិរីរួមទាំងយុវជនខ្មែរពីររូបតំណាងអង្គការក្រៅរដ្ឋាភិបាលNGOFORUM ពីកម្ពុជាទៅចូលរួមផងដែរ។

លោក ថាច់ ង៉ុក ថាច់ ប្រធានសហព័ន្ធខ្មែរកម្ពុជាក្រោមមានប្រសាសន៍ឲ្យដឹងបន្ថែមអំពីរបៀបវារៈ នៃកិច្ចប្រជុំអំពីកម្ពុ៖ «*របៀបវារៈរបស់គេនិយាយពីបញ្ហាការរើសអើងហ្នឹង ដោយមានចោទច្រើនមាត្រា នៅក្នុងប្រទេសខ្មែរហ្នឹងចំពោះខ្មែរក្រោម។ មាត្រាទី១ មាត្រាទី៤ មាត្រាទី៥ មាត្រាទី៦ មាត្រាទី៧ គឺទាក់ទងនឹងបញ្ហាយុត្តិធម៌ ដូចជាបញ្ហាព្រះតេជគុណ សុខ ធឿន ដែលត្រូវបានធ្វើគត គេបានសួររដ្ឋាភិបាលខ្មែរថា តើពេលណាបានយកបញ្ហាហ្នឹងមកតុលាការ? ទី២គឺបញ្ហាការរើងអើង ដោយគេយកបញ្ហាលោកគ្រូ ទឹម សាខន ដែលថារដ្ឋាភិបាលខ្មែរទទួលស្គាល់ជាខ្មែរហើយហេតុអីបានចាប់បញ្ជូនទៅប្រទេសយួនដាក់គុក? ទី៣គឺបញ្ហាអត្តសញ្ញាណប័ណ្ណ ដែលបងប្អូននៅខេត្តតាកែវ កំពង់ឆ្នាំង កំពត កំពង់សោម មិនបានធ្វើអត្តសញ្ញាណប័ណ្ណឲ្យជាទូទៅហ្នឹង ហ្នឹងវាទាក់ទងដល់ការទៅមន្ទីរពេទ្យ ការសិក្សាអប់រំចំពោះកូនចៅ។ នៅក្នុងហ្នឹងយើងឃើញថា ខាងរដ្ឋាភិបាលខ្មែរ តំណាងមកពីរាជរដ្ឋាភិបាលគ្មានទេ មានតែតំណាងទូត*»។

នៅក្នុងកិច្ចប្រជុំនោះលោកឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសស្វ៊ីសបានអញ្ជើញទៅឆ្លើយបំភ្លឺតបចំពោះការចោទប្រកាន់ ដែលថាជនជាតិដើមភាគតិច ដូចជាខ្មែរកម្ពុជាក្រោមនិងជនជាតិដើមភាគតិចរួមមាន គួយ ចារ៉ាយ ជាដើមនោះ កំពុងរងការរើសអើងក្នុងសង្គមកម្ពុជានៅពេលបច្ចុប្បន្ន។

លោក ថាច់ ង៉ុកថាច់ មានប្រសាសន៍ថា ៖ *រដ្ឋាភិបាលខ្មែរគាត់ឆ្លើយដោយលោកឯកអគ្គរាជទូត ស៊ុនសួន ហើយជាមួយនឹងសហការីគាត់៣នាក់ទៀត ដែលជម្រាបមកហ្នឹង គឺនិយាយដោះស្រាយពីបញ្ហាជនជាតិដើមពួក ព្នង គួយ ... ដោយគាត់បានជម្រាបថា មានច្បាប់អីគ្រប់គ្រាន់ទាំងអស់ សម្រាប់ទាំងពីរផ្នែកសិក្សាអប់រំ ស្ត្រី កុមារ រឿងដីធ្លី ហ្នឹងផ្នែកខាងគាត់ ហើយការបកស្រាយ ការនិយាយហ្នឹងអស់ប្រហែលជាមួយម៉ោងម្ភៃ។ ខ្ញុំមើលឃើញទៅដូចជាមិន*(**តទៅទំព័រទី២៤**)

តមកពីទំព័រទី២៣) *មានស្ត្រីក្រៅពីគាត់សម្រួលធ្វើម៉េច ឲ្យតែបានរួចខ្លួនមួយពេលតែប៉ុណ្ណឹងទេ។ យើងឃើញគួរឲ្យស្តាយ ដូចខ្ញុំបានជំរាបអ៊ីចឹង មិនមានអ្នកតំណាង ដែលទទួលខុសត្រូវមក ហើយឲ្យអស់លោកដែលតំណាងទូតនៅទីនេះ ដែលកិច្ចការមួយចំនួនដែលគាត់មិនបានដឹង។ ចំពោះរឿងខ្មែរក្រោមវិញគាត់បាននិយាយអំពីបញ្ហាធ្វើអត្តសញ្ញាណប័ណ្ណបញ្ហាខ្មែរក្រោមដែល មកនៅប្រទេសខ្មែរហ្នឹង រាជរដ្ឋាភិបាលនៅក្នុងរដ្ឋធម្មនុញ្ញបានថា ឲ្យក្លាយទៅជាខ្មែរហូរហែអ៊ីចឹង។លោក ស៊ុន សួន លោកថារាជរដ្ឋាភិបាលខ្មែរនឹងខិតខំទាក់ទងគ្នាជាមួយនឹងរដ្ឋាភិបាលយួនធ្វើយ៉ាងណា ដើម្បីដោះស្រាយបញ្ហាខ្មែរក្រោមនូវរឿងអត្តសញ្ញាណប័ណ្ណរឿងការរស់នៅឬការឆ្លងដែនហ្នឹង»។*

វិទ្យុអាស៊ីសេរីនៅមិនទាន់អាចទាក់ទងស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសស្វ៊ីស ដើម្បីសុំសេចក្តីបញ្ជាក់ពីរឿងនេះ បាននៅឡើយទេនៅពេលនេះ។ចំណែកលោក ជិន ថារ៉ូ តំណាងឲ្យអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដែលបានទៅចូលរួមក្នុងសន្និសីទនោះដែរមានប្រសាសន៍ថា ៖

*«មកនេះគឺយើងតំណាងឲ្យជនជាតិទាំង២០ជនជាតិដែលមាននៅក្នុងប្រទេសកម្ពុជាហ្នឹង គឺមាន៣ ដែលអញ្ជើញមកហ្នឹង គឺមានជនជាតិចារ៉ាយ គាត់អញ្ជើញមកពីខេត្តរតនគិរី នៅស្រុកអូរយ៉ាដាវ ហើយជនជាតិគួយ គាត់អញ្ជើញមកពីខេត្តកំពង់ធំ ដែលជាអ្នកតំណាងឲ្យជនជាតិដែលនៅខេត្តព្រះវិហារឬក៏ខេត្តកំពង់ធំហើយមួយទៀត គឺគាត់អញ្ជើញមកពីខេត្តមណ្ឌលគិរី គឺជនជាតិព្នង។ ការសន្យារបស់រាជរដ្ឋាភិបាលមើលទៅដូច ជាមិនទាន់មានអីជាការសន្យាឲ្យច្បាស់លាស់ គ្រាន់តែគាត់និយាយជាទូទៅលើការដែលថា រដ្ឋាភិបាលបានមានច្បាប់ ដែលពាក់ព័ន្ធទៅលើការលើកកំពស់ ឬការគាំទ្រទៅដល់ជនជាតិដើមភាគតិចអ៊ីចឹង»។*

លោក ថាច់ ង៉ុកថាច់ បញ្ជាក់ថាចំពោះករណីខ្មែរកម្ពុជាក្រោមវិញ បើរដ្ឋាភិបាលកម្ពុជាមិនដោះស្រាយផ្តល់អត្តសញ្ញាណខ្មែរឲ្យខ្មែរក្រោម ដែលមករស់នៅក្នុងប្រទេសកម្ពុជាទេនោះ អង្គការសហប្រជាជាតិអាចនឹងជំរុញឲ្យរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាពលរដ្ឋខ្មែរក្រោមដែលរត់ចូលមកកម្ពុជានោះជាជនភៀសខ្លួន ដើម្បីផ្តល់លទ្ធភាពដល់អង្គការ UNHCR ប្រចាំកម្ពុជាអាចជួយពលរដ្ឋខ្មែរក្រោមក្នុងនាមជាជនភៀសខ្លួននយោបាយ៕

**ប្រភព RFA**

---

**(តមកពីទំព័រទី១៣)** ដូចជា *(ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ន)*ជាដើម ដែលជាស្នាព្រះហស្តរបស់ព្រះអង្គ។ នៅសម័យឆ្នាំ១១៨០ព្រះសង្ឃខ្មែរមួយរូបជាបុត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ ព្រះនាមតាមលិន្ទបានទៅសិក្សាភាសាបាលីនិង ចំណេះដឹងផ្នែកព្រះពុទ្ធសាសនានៅកោះសេរីលង្កា ហើយបាននាំចូលចំណេះដឹងទាំងនេះមកវិញនៅអំឡុងឆ្នាំ១១។ព្រះអង្គបានទទួលមរណៈនាមថា **មហាបរមសៅគត**។ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់ផ្ទាល់ជាពុទ្ធសាសនិកមហាយានដែលជាភស្តុតាងបញ្ជាក់កាន់តែច្បាស់ថាពុទ្ធសាសនាថេរវាទបានរីកចម្រើនរុងរឿងខ្លាំងនៅសម័យនោះ។ បេសកកម្មរបស់ពួកចិននៅសម័យនោះមកកាន់ក្រុងអង្គរ ដែលដឹកនាំដោយ Chou Ta-Kaun នៅឆ្នាំ១២៩៦-១២៩៧ បានកត់សម្គាល់ឃើញមានព្រះសង្ឃពុទ្ធសាសនាថេរវាទនៅលើទឹកដីនេះ។

•**ពុទ្ធសាសនានៅសម័យចុងអង្គរ** គេបានដឹងមកហើយដែរថា ព្រះពុទ្ធសាសនាថេរវាទនេះរីកចម្រើនតាំងពីរាជព្រះបាទជ័យវរ្ម័នទី៧មកម៉្លេះដោយទ្រង់បានបញ្ជូនបុត្ររបស់ទ្រង់ ព្រះនាមតាមលិន្ទទៅបួសជា(**តទៅលេខក្រោយ**)

# កំពូលអាហារជួយលាងជាតិពុល

ឈ្មោះថា អាហារលាងជាតិពុលធ្វើឲ្យមនុស្ស យ៉ាងច្រើនប្រាកដជានឹកថា រកបរិភោគបានយ៉ាងលំបាកហើយ ប៉ុន្តែសំរាប់អាហារបន្លែទាំងនោះយើងអាចរកហូបបានដោយងាយ សូមអញ្ជើញមើល និងពិចារណាទាំងអស់គ្នាថាមានអ្វីខ្លះ ៖

**មើមខ្ទឹមបារាំង:** ជាមើមប្រកបទៅដោយសារប្រយោជន៍ទប់ទល់ប្រឆាំងនឹងជំងឺមហារីកជាច្រើនប្រភេទ ជួយធ្វើឲ្យស្អាតគ្រាប់ឈាម បញ្ចុះជាតិកូលេសស្តេរ៉ូល បន្ថយមិនឲ្យកើតជំងឺបេះដូង ក្រៅពីនេះនៅជួយធ្វើឲ្យប្រព័ន្ធផ្លូវដង្ហើមធ្វើការបានល្អឡើង ព្យាបាលរោគដង្ហក់ផ្លូវដង្ហើម ហើយសំខាន់ជាងនេះ គឺព្យាបាលរោគទឹកនោមផ្អែមបានដោយធ្វើឲ្យលំដាប់ជាតិស្ករធ្លាក់ចុះ។

**សារាយ:** ជារុក្ខជាតិពណ៌បៃតងដុះក្នុងសមុទ្រ ដែលមនុស្សជាច្រើនមើលរំលង តែលទ្ធផលការសិក្សារបស់មហាវិទ្យាល័យ Mc Gill ក្នុងក្រុង (Montreal) ប្រទេសកាណាដា បញ្ជាក់ច្បាស់ថា សារាយអាចស្រូបជញ្ជក់របស់ខូចពីពន្លឺ ដែលនឹងសន្សំក្នុងរាងកាយបានយ៉ាងមានប្រសិទ្ធភាព មិនថាជាពន្លឺពីរលកវិទ្យុរំញ័រទូរស័ព្ទ រំញ័រមេដែកអគ្គិសនី ឬរលកមៃក្រូវេ ដែលថាមពលធាតុក្តៅពីពន្លឺដូចពោលនេះ អាចកើតរោគមហារីកបាន។ ក្រៅពីនេះសារាយនៅមានជាតិប្រូតេអ៊ីន និងធាតុអំបិលរ៉ែមានចំនួនច្រើនទៀតផង ។

**គ្រាប់ពុតលិញង៖** គ្រាប់ពុតលំញងនេះមានឧត្តមភាព ជួយស្រូបជាតិខ្លាញ់ក្នុងអាហារចេញពីរាងកាយសម្បូរទៅដោយជាតិវីតាមីនCនិងមានសារធាតុប្រឆាំងជាតិពុល និងជាតិពុលកម្រិតខ្ពស់ជួយកម្ចាត់របស់ខូចចេញពីប្រព័ន្ធអាហារបានយ៉ាងឆាប់រហ័ស ។

**ការ៉ុត:** មានឧត្តមភាពសម្បូរទៅដោយសារធាតុរបស់វីតាមីន A ជួយប្រឆាំងជំងឺផ្សេងៗ បានយ៉ាងល្អប្រសើរ អាហាររាងកាយប្រឆាំងសារជាតិពុល ដោយទ្បែកជំនួសថាមពលដល់សរសៃប្រសាទកែវភ្នែក និងជំនួយស្បែកឲ្យមានភាពស្រស់ថ្លា ទោះបីធ្វើដំណើរត្រូវខ្យល់និង កម្តៅថ្ងៃយ៉ាងណាក៏ដោយ ។




បន្លែគ្រប់មុខសម្រាប់ជួយលាងជាតិពុល

**រុក្ខជាតិពូជសណ្តែក:** មិនថាសណ្តែកសៀង ឬសណ្តែកក្រហមសណ្តែកខៀវ ឬសណ្តែកផ្សេងៗ សុទ្ធតែមានគុណសម្បត្តិជួយសម្អាតពោះវៀន បញ្ចុះជាតិពុលក្នុងពោះវៀន និងជួយគ្រប់គ្រងលំដាប់ជាតិស្ករក្នុងខ្លួនយើងឲ្យនៅក្នុងកម្រិតធម្មតា និងអាចបន្ថយអត្រាចំពោះការកើតជំងឺបេះដូងមហារីកពោះវៀន និងជំងឺមហារីកមាត់ស្បូនបាន។

**ត្រប់ខា:** ជាតិទឹកត្រប់មានគុណសម្បត្តិនឹងជួយសម្អាតជាតិបាក់តេរី និងជួយប្រព័ន្ធផ្លូវបន្ទោបង់ (ផ្លូវទឹកនោម) ដែលរមែងធ្វើឲ្យកើតការចម្លងរោគ បណ្តាលពីអាការៈឈឺនោមមិនចេញ មានឈាមហូរមកជាមួយ ឬមានអាការៈឈឺពោះយ៉ាងខ្លាំង ។

**ផ្លែក្រូចឆ្មារ:** ជាកំពូលអាហារជួយធ្វើភាពស្អាតចំពោះថ្លើម និងសម្បូរទៅដោយវីតាមីនខ្ពស់។ ការផឹកទឹកក្រូចស្រស់លាយជាមួយ.........។**(តទៅទំព័រទី២៨)**

# ព័ត៌មានកីឡាជាតិ និង អន្តរជាតិ



រូបភាពទាំងនេះត្រូវបានផ្សាយដោយវេបសាយបរទេស កាលពីខែមករា ឆ្នាំ២០១០ ដែលបង្ហាញពីកន្លែងវាយតេនីសខ្ពស់ជាងគេបំផុត នៅលើពិភពលោក ។ វាស្ថិតនៅលើកំពូលអាគារ Dubai ហើយត្រូវបើកសម្ពោធលេងក្នុងការប្រកួត Dubai Duty free Men's Open នាឆ្នាំ ២០០៦ មកម្ល៉េះ៕



ការប្រកួតអូឡាំពិក Vacouver ២០១០ នៅកាណាដា បានប្រព្រឹត្តទៅនៅថ្ងៃទី ១២ ដល់ ថ្ងៃ ២៨ ខែកុម្ភៈ ឆ្នាំ២០១០ ដោយមានកីឡាករការិនីជិត ១០០ ប្រទេសមកចូលរួម ប៉ុន្តែបើគិតពីការផ្តើមប្រកួត រហូតមកដល់ថ្ងៃនេះ តាមតារាងមេដាយផ្សាយដោយវេបសាយបរទេសនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១០ បានឲ្យដឹងថាអាមេរិកបានមេដាយច្រើនជាងគេចំនួន២៦អាឡឺម៉ង់បាន២៣ ណ័រវ៉េ បន្ទាប់បាន១៧៕



អតីតកីឡាករឆ្នើមរបស់ប្រេស៊ីល ប៉ឺឡេ

អតីតកីឡាករឆ្នើមរបស់ប្រេស៊ីល ប៉ឺ ឡេ បាននិយាយថា ការប្រកួតបាល់ទាត់World Cup 2010 នេះ គួរប្រើប្រាស់មន្ត្រីអាជ្ញាកណ្តាលចំនួន៥រូបដោយបន្ថែមចំនួន២រូបទៀតនៅពីក្រោយបង្គោលទីក្នុងគោលបំណងត្រួតពិនិត្យមើលការស៊ុតបាល់បញ្ចូលទី ដើម្បីចៀសវាងកុំឱ្យកើតមានរឿងអាស្រូវ ដូចកាលពីឆ្នាំ១៩៨៦ នៅពេលដែលកីឡាករ ម៉ារ៉ាដូណា ប្រើប្រាស់ដៃទះបាល់បញ្ចូលទី និងរឿងរ៉ាវថ្មីៗដែលបានកើតឡើងចំពោះកីឡាករ ហង់រី ក្នុងការប្រកួតជំរុះ World Cup វគ្គ Play off រវាងក្រុមបារាំង និងអៀរឡង់ ។

លោក ប៉ឺ ឡេ បាននិយាយបន្ថែមទៀតថា លោកមានការពេញចិត្តយ៉ាងខ្លាំង ចំពោះការប្រើប្រាស់អាជ្ញាកណ្តាល៥រូប ប៉ុន្តែគំនិតនេះវាហាក់ដូចជាប្រឆាំងទៅនឹងបច្ចេកវិទ្យាសម័យទំនើបដែលមានប្រព័ន្ធវីដេអូចាប់រូបភាពក្នុងអំឡុងពេលប្រកួត ហើយនឹងមានការចាក់ផ្សាយសាឡើងវិញនៅពេលដែលកីឡាករប្រព្រឹត្តកំហុស។រហូតមកដល់ពេលនេះមិនទាន់មានការឆ្លើយតបជាផ្លូវការណាមួយពីលោកSepp Blatter ប្រធានសហព័ន្ធបាល់ទាត់ FIFA នៅឡើយទេតែសហព័ន្ធបាល់ទាត់អឺរ៉ុប មានគំរោងធ្វើការពិសោធន៍ដោយប្រើប្រាស់អាជ្ញាកណ្តាល៥រូប នៅក្នុងការប្រកួតបាល់ទាត់យូហ្វាខាប់រដូវកាលនេះ។

លោក Sepp Blatter បាននិយាយថា សំណើរបស់លោកប៉ឺឡេនេះវាមិនមែនជារឿងថ្មីនោះទេ ព្រោះកន្លងមកវាធ្លាប់ត្រូវបានគេលើកសំណើឡើងតាំងពីឆ្នាំ១៩៨៦ ម្តងរួចមកហើយ នៅពេលដែលកីឡាករម៉ារ៉ាដូណា ក្រុមអាហ្សង់ទីន ប្រើប្រាស់ដៃទះបាល់បញ្ចូលទី យកឈ្នះក្រុមអង់គ្លេស ២-១ ក្នុងវគ្គ ១/៤ នៃការប្រកួតបាល់ទាត់ World Cup ។ លោក Sepp Blatter បាននិយាយដោយទំនុកចិត្តថា ទោះបីជាអាជ្ញាកណ្តាល៥រូប ប្រហែលជាមិនត្រូវបានប្រើប្រាស់ក្នុងការប្រកួតបាល់ទាត់ World Cup ឆ្នាំ២០១០នេះក្តី តែលោកសង្ឃឹមថា ការប្រកួតបាល់ទាត់ World Cup នៅអាហ្វ្រិកខាងត្បូងនឹងមិនមានរឿងអាស្រូវ បែបនេះកើតឡើងជាថ្មីទៀតនោះទេ ព្រោះអាជ្ញាកណ្តាលនីមួយៗត្រូវបានជ្រើសរើសដោយសំរិតសំរាំង និងមានសីលធម៌វិជ្ជាជីវៈខ្ពស់ក្នុងការងារ៕

# រឿងរ៉ាវប្លែកៗនៅជុំវិញពិភពលោក



Kola Peninsula ជាឈ្មោះ ជ្រោយឆកសមុទ្រមួយនៅភាគពាយព្យ រុស្ស៊ី ជាប់ព្រំប្រទល់ប្រទេស ណ័រវ៉េ និង ហ្វាំងឡង់ ហើយត្រូវគេហៅថា ជាទីក្រុងខ្មោច ព្រោះទីតាំងនេះជាអតីតមូលដ្ឋានទ័ពរុស្ស៊ី ដែលត្រូវគេបោះបង់ចោលតាំងពីឆ្នាំ ១៩៩០ មកម្ល៉េះ។



តាមវេបសាយបរទេសកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១០ បានប្រមែប្រមូលនូវភាព និងពណ៌នាបង្ហាញនូវបន្ទប់ទឹកចម្លែកបំផុត នៅលើពិភពលោក ហើយបន្ទប់ទឹកស្រាបៀរនេះ ជួយឲ្យស្បែករបស់អស់លោកអ្នកស្អាត់រលោងនិងរក្សាសម្រស់ឲ្យនៅក្មេងជាងវ័យ។ នេះហើយធ្វើឲ្យមនុស្សម្នាជាច្រើនចាប់អារម្មណ៍យ៉ាងខ្លាំង។



ស្ពានដែលមានប្រវែងវែងជាង ២ គីឡូម៉ែត្រ (គម) ត្រូវបានគេចាត់ទុកជាស្ពានវែងជាងគេ ប៉ុន្តែ ពេលនេះយើងសូមបង្ហាញជូននូវស្ពានដែលវែងជាងគេមួយក្នុងចំណោមស្ពានទាំង១០ នៅក្នុងពិភពលោក ដែលផ្សព្វផ្សាយដោយវេបសាយបរទេសកាលពីពេលថ្មីៗនេះ ។ នេះហើយជាស្ពាននៅប្រទេសចិនសព្វថ្ងៃ។



តាមវេបសាយបរទេសផ្សាយនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១០ ដោយបង្ហាញពីក្តាមសមុទ្រធំបំផុតក្នុងលោក នៅអង់គ្លេសដែលជើងរបស់វាវែងជាងជើងមនុស្សទៅទៀត។ ក្តាមចម្លែកនេះ បើតាមអ្នកជំនាញជឿថា អាចលូតលាស់ធំហើយជើងក៏វែងជាងហ្នឹងទៀតផង។ ក្តាមនេះមានដង្កៀបប្រវែង ១០ ហ្វីត ពីដង្កៀបមួយទៅដង្កៀប ឬ ថ្នាំងមួយ ហើយត្រូវនេសាទពីក្នុងសមុទ្រប៉ាស៊ីហ្វិក ហើយសព្វថ្ងៃគេដាក់នៅ Birmingham ។



ទីក្រុងនៅប្រទេសអ៊ីតាលី

ដោយសារចំណេះដឹងសមត្ថភាពទេពកោសល្យដ៏ទូលំទូលាយរបស់មនុស្សធ្វើឲ្យសមិទ្ធិផលអស្ចារ្យនានា បានផុសឡើងជាបន្តបន្ទាប់នៅលើពិភពលោកគួរឲ្យកោតស្ញប់ស្ញែងក្រៃលែង។ជាក់ស្តែងកាលពីពេលថ្មីៗនេះ តាមវេបសាយបរទេសមួយបានផ្សាយឲ្យដឹង និង បង្ហាញទីក្រុងដ៏អស្ចារ្យដែលសង់លើគែមកំពូលច្រាំងថ្មចោតខ្ពស់បំផុតក្នុងលោក ដែលមើលទៅហាក់ដូចជាពួកគេកំពុងរស់នៅក្នុងភាពប្រឈមនិង ប្រថុយប្រថានមួយ ។

(តមកពីទំព័រទី២៥) ទឹកក្តៅឧណ្ហៗរាល់ព្រឹកក្រោយពីភ្ញាក់ពីដំណេកនឹងអាចជួយលាងជាតិពុល និងធ្វើឲ្យសរសៃឈាមដើរស្រួល តែបើយកទឹកក្រូចឆ្មារផ្សំជាមួយទឹកឃ្មុំនឹងជួយលាងពុលក្នុងពោះវៀន ហើយជួយការពារជំងឺពោះវៀនដុះខ្នែងបានទៀតផង ។

**ខ្ទឹមស:** ខ្ទឹមសជួយសម្លាប់មេរោគបាក់តេរី និងសម្លាប់ព្ពូនរួមទៅដល់ការកម្ចាត់វីរុស (Virus) ក្នុងបំពង់អាហារបានយ៉ាងល្អប្រសើរព្រមទាំងប្រឆាំងជំងឺមហារីក និងធ្វើឲ្យផ្លូវដកដង្ហើមធ្វើការបានល្អថែមទៀតផង ។

**ផ្កាស្ពៃ:** ជំនួយថ្លើមបង្កើនអ័រម៉ូនបានច្រើន ថែមទាំងជួយសម្អាតរបបរំលាយអាហារជួយព្យាបាល និងការពារក្រពះអាហារពីបាក់តេរី និងវីរុសផ្សេងៗ ដោយរួមមានពូជរុក្ខជាតិស្ពៃដូចជា ស្ពៃក្តោប ផ្កាខាត់ណា ស្ពៃចង្កឹះ ស្ពៃឈ្មួលជាដើម។

**ស្លឹកច្បាស:** ស្លឹកពណ៌បៃតងដែលអាចដុះឡើងតាមរបងរកបានងាយ និងតម្លៃថោកមានគុណសម្បត្តិជួយផលិតជាតិទឹកក្នុងរាងកាយនិងកម្ចាត់ជាតិពុលចេញពីខ្លួនមនុស្សយើងបានយ៉ាងល្អប្រសើរ។ក្រៅពីនេះ ស្លឹកបាសជួយកាត់បន្ថយជាតិស្ករ និងជួយឲ្យថ្លើមរំលាយជាតិខ្លាញ់ឲ្យខ្លួនឯងបានល្អទៀតផង ។

**ផ្លែចេក:** រកហូបបច្ចុពិសា បានយ៉ាងងាយបំផុតតម្លៃថោក តែមានគុណប្រយោជន៍ច្រើនយ៉ាង គឺសម្បូរទៅដោយជាតិរ៉ែ និងវីតាមីនA វីតាមីនB6 និងB10 វីតាមីនC ប្រូតេអ៊ីនកាល់ស្យូម សូដ្យូម និងជាតិដែក ។ ក្រៅពីនេះចេកជួយឲ្យមានភាពរឹងមាំរាងកាយព្រមទាំងជួយសម្រួលការលាយអាហារដល់ក្រពះបានយ៉ាងល្អ ។ ផ្លែចេកមានសារធាតុស្រ្តិបតូផេន ដែលជាសារជាតុរួមផ្សំជួយដល់សរសៃប្រសាទឲ្យមានអារម្មណ៍ស្ងប់ ជួយឲ្យសម្រាន្តលក់ស្រួល ។ បើយើងហូបចេកជាប្រចាំវាអាចជួយបាននូវជំងឺចុកពោះ និងបន្ទោបង់បានល្អថែមទៀតផង ៕

**ឯកសារស្រាវជ្រាវ**

---

(តមកពីទំព័រទី២០) បង់ទៅអាជ្ញាធរ ដើម្បីបញ្ចប់នីតិវិធីច្បាប់ធ្វើអត្តសញ្ញាណប័ណ្ណ និងឯកសារផ្សេងៗនោះ។ស្ត្រីរូបនេះមានប្រសាសន៍ឲ្យដឹងទៀតថា កន្លងមកពួកគេទទួលរងជំងឺដ៏ចំឡែក ប៉ុន្តែគ្មានសមត្ថកិច្ចណាឈឺក្បាលហាលថ្ងៃទេ រីឯកាកបាទក្រហមកម្ពុជាធ្វើមិនដឹងមិនឮទៀត ។ស្ត្រីឈ្មោះ ង៉ុក បានអំពាវនាវដល់មន្ត្រីអង្គការសិទ្ធិមនុស្សជួយអន្តរាគមន៍ និងជួយជំរុញឲ្យរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ដល់ពួកគេ ។

គួររំលឹកជូនថា កន្លងមកអតីតព្រះចៅអធិការវត្តភ្នំដិនខាងជើង លោក ទឹម សាខន ត្រូវក្រុមអាជ្ញាធរ និងក្រុមសម្តេចសង្ឃកម្ពុជា ចាប់ផ្សឹករួចបញ្ជូនទៅដាក់គុកនៅប្រទេសវៀតណាម។ ក្រោយពីអតីតសង្ឃរូបនេះ បានទៅដល់ទឹកដីកម្ពុជាក្រោម ក្រុមអាជ្ញាធរកម្ពុជាអះអាងនិងសន្យាថា រដ្ឋាបាលបានទទួលស្គាល់លោក ទឹម សាខនជាពលរដ្ឋខ្មែរ ហើយនឹងផ្តល់ឯកសារពាក់ព័ន្ធផ្សេងៗតាមនីតិវិធីច្បាប់។ជាអកុសលទឹម សាខនមិនត្រូវបានគេផ្តល់សិទ្ធិឲ្យរស់នៅក្នុងប្រទេសកម្ពុជាឡើយ។ ក្រោយមក លោកទឹម សាខន ត្រូវបង្ខំចិត្តរត់ទៅសុំសិទ្ធិជ្រកកោនពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅប្រទេសថៃ។ បន្ទាប់មកក៏ត្រូវបានគេបញ្ជូនទៅរស់នៅប្រទេសទី៣។ លោក ទឹម សាខន ធ្លាប់បានរិះគន់រដ្ឋាបាលកម្ពុជាតាមរយៈវិទ្យុសំឡេងកម្ពុជាក្រោមថា លោកមិនជឿរដ្ឋាភិបាលកម្ពុជាជាដាច់ខាត។ព្រោះរដ្ឋាភិបាលកម្ពុជាសព្វថ្ងៃនេះ ឋិតនៅក្រោមខ្សែញាក់របស់ក្រុងហាណូយ។ ដូច្នេះ លោកមានការព្រួយបារម្ភពីជោគវាសនានៃក្រុមជនភៀសខ្លួនខ្មែរក្រោមទាំងនោះ៕ **ដោយ ថៅ មុនី ខេមរា**

(តមកពីទំព័រទី២១)



សម្តេចសង្ឃ ដាឡៃ ឡាម៉ា ធ្វើសន្និសីទកាសែត នៅវ៉ាស៊ីនតោន

ល័យព្រឹទ្ធសភាអាមេរិក នៅរដ្ឋធានីវ៉ាស៊ីនតោន។ មានអ្នកចូលរួមប្រមាណ ៥០០អង្គនិងរូប ក្នុងនោះដែរយើងសង្កេតឃើញមានលោក Richard Gera តារាភាពយន្តដ៏ល្បីនិងលោកតំណាងអ្នកដឹកនាំជនជាតិដើម Uighurs ព្រមទាំងអ្នកនយោបាយជាច្រើនរូបទៀត។

ស្របពេលនោះដែរ ថ្នាក់ដឹកនាំសហព័ន្ធ បានទៅជួបជាមួយមន្ត្រីតំណាងអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនស្តីពីបងប្អូនខ្មែរក្រោមដែលត្រូវអាជ្ញាធរសៀមចាប់បញ្ជូនទៅកាន់កម្ពុជាវិញក្នុងពេលថ្មី ៗនេះ នឹងសូមឲ្យមន្ត្រី UNHCR ធ្វើការពិនិត្យ និងសើរើនូវសំណុំរឿងទាំងនោះ ជាពិសេសករណីមួយចំនួន ដែលមានសភាពធ្ងន់ធ្ងរ ជាប់ទាក់ទងជាមួយទោសនយោបាយជាដើម។

នៅក្នុងថ្ងៃដដែលនោះលោក ត្រឹង ម៉ានរិនប្រធានគណៈប្រតិភូ មានកិត្តិយស បានជួបផ្ទាល់ជាមួយសម្តេចសង្ឃ ដាឡាយ ឡាម៉ានៅក្នុងបណ្ណាល័យព្រឹទ្ធសភាសហរដ្ឋអាមេរិក ដើម្បីស្វែងយល់និងដកស្រង់យកបទពិសោធក្នុងការទាមទារសិទ្ធិជនជាតិដើមនិងសិទ្ធិស្វយ័តនៃដែនដីទីបេ។ នៅក្នុងកិច្ចសំណេះសំណាលនោះ ព្រះអង្គបានមានសង្ឃដីកាថា រឿងកម្ពុជាក្រោមនិងរឿងដែនដីទីបេគឺដូចគ្នា ពីព្រោះទន្លេមេគង្គចាប់ផ្តើមចេញពីទីបេ ហើយបញ្ចប់នៅឯកម្ពុជាក្រោម ប្រជាពលរដ្ឋខ្មែរក្រោមគោរពប្រតិបត្តិព្រះពុទ្ធសាសនា នៅទីបេក៏គោរពព្រះពុទ្ធសាសនា រីឯទីបេត្រូវចិនត្រួតត្រា ចំណែកខ្មែរក្រោមវិញត្រូវយួនត្រួតផងដែរ។ព្រះអង្គបានបញ្ជាក់ទៀតថា ការទាមទារសិទ្ធិគឺត្រូវការពេលវេលាយូរអង្វែង និងស្វិតស្វាញ ហើយប្រកបដោយសន្តិវិធី។

លោកអគ្គនាយកផែនការបានជំរាបជូនសាធារណជនដូច្នេះទៀតថា ការវិវដ្តរបស់សង្គមមនុស្សទូទៅនិងការវិវដ្តនៃប្រទេសវៀតណាមក៏អញ្ចឹងដែរដោយសារការឈានទៅរកលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សនិងការគោរពសិទ្ធិជនជាតិដើមនឹងធ្វើយ៉ាងណាឲ្យខ្មែរយើងយល់ដឹងនូវសិទ្ធិរបស់ខ្លួនច្បាស់លាស់ ពេលនោះពួកគាត់នឹងហ៊ានទាមទារនូវសិទ្ធិសេរីភាព។

ចុងបញ្ចប់លោកអំពាវនាវដល់ខ្មែរកម្ពុជាក្រោមនៅក្នុងស្រុកត្រូវខំប្រឹងព្យាយាមស្រាវជ្រាវរៀនសូត្រនូវច្បាប់របស់អង្គការសហប្រជាជាតិ និងច្បាប់នៃប្រទេសវៀតណាម ហើយកុំធ្វើអ្វីផ្ទុយពីច្បាប់ទាំងនេះ នាំឲ្យពួកគេប្រើល្បិចចាប់ដាក់គុកជាដើម៕

**ដោយ កូនខ្មែរ**

---


## ប្រេងខ្យល់ប្រទាលខ្មែរបុរាណ

**វិធីប្រើ៖** លាបនៅពេលដែលចុកដៃជើង, ស្ពឹកស្រពន់, ចុកចង្កេះ, ថ្លោះគ្រិច, ឈឺក្បាល, វិលមុខ, ពុលឡានពុលកាណូត, ពុលយន្តហោះ, ចុកពោះ, ឆ្អល់ពោះ, ហើមពោះ, ណែនពោះ, តឹងប្រមុះ, ផ្តាសាយ, មូសខាំ, ក្អែកខាំស្រាំងទិច, ឱម៉ាលទិច, ទ្បើងកន្ទួល, រម៉ាស់ផ្សេងៗ.......។ **បញ្ជាក់៖** *ហាមយកប្រេងខ្យល់នេះទៅលាបភ្នែក។*

**លោក អ្នក ចង់បានប្រេងខ្យល់ប្រទាលខ្មែរបុរាណ សូមទំនាក់ទំនងទូរស័ព្ទលេខ៖ (408) 923-2166**

# ពេលដែលត្រូវយំ

១-ជាតិមនុស្សក្នុងលោក ចង់តែសើច ការកុំឲ្យខើច អាយុខ្លី
ណាត់គ្នាស៊ីផឹក លេងសម្តី ស្តាប់ល្ខោន អាយ៉ៃ ឆាកកំប្លែង។
២-បើយំ គេឃើញ គឺមនុស្សខ្សោយ ត្រូវយំក៏ដោយ យំម្នាក់ឯង
ក្នុងទីប្រជុំត្រូវខែងរ៉ែង ស្រវឹងគេសែង ក៏កុំយំ។
៣-ប៉ុន្តែមានខ្មែរមួយចំនួន យំមិនដឹងខ្លួនរាល់ប្រជុំ
ភ្លេងជាតិពេលចិត្តអួលរងំ ក្តុកក្តួលទុក្ខធំទ្រាំមិនបាន។
៤-ខ្មែរក្រោមជួបជុំយំរាល់ឆ្នាំ យំជាប្រចាំមិនដែលខាន
ទឹកភ្នែកហៀរហូរ ហួសពីស្មាន យំស្រយុតប្រាណណែនឱរា។
៥-បើកឡានច្រើនម៉ោង ហោះឆ្លងរដ្ឋ អាមេរិក រហូតអូស្ត្រាលីយ៉ា
អឺរ៉ុប អាស៊ី កាណាដា ជួបគ្នាកាលណានាំគ្នាយំ។
៦-យំទាំងអ្នកថ្លែង ទាំងអ្នកស្តាប់ យំចិត្តឈឺចាប់ ទុក្ខប៉ុនភ្នំ
ទង់ជាតិ សាសនា ភ្លេងរងំ ខ្មែរក្រោមទុក្ខធំត្រូវគេជាន់។
៧-រាល់ឆ្នាំប្តូរទីយំគ្រប់គ្នា តាមរដ្ឋនានាសហព័ន្ធ
តំណក់ទឹកភ្នែកតជំនាន់ យំហើយរួសរាន់ដោះបញ្ហា។
៨-បងប្អូនជាតិខ្មែរ រួមលោហិត បើមិនអាណិត សូមមេត្តា
យកទឹកភ្នែកខ្មែរ ពិចារណា កុំភ្លេចជួបគ្នារកសេរី។
៩-ទាំងខ្មែរដែលជាប់មាត់ប្រឹងសើច សើចភ្លេច ពេលខើច ជិតអស់ដី
មើលទុក្ខខ្មែរក្រោម ទាំងប្រុសស្រី ប្រយ័ត្នគិតខ្លី យំឆ្លងគ្នា។
១០-ជាតិយើងតែមួយ មហានគរ ម្តេចប្រែរឹករវ បែកឃ្លាតឃ្លា
មានយំ មានសើច រឿងកម្ពុជា ថ្ងៃណា សាមគ្គា ឯកភាពបាន។

ដោយ ព្រឹទ្ធាចារ្យ ស៊ឹង សម្រេច

# រាសីប្រចាំខែមីនា

**១.ឆ្នាំជូត:** រាសីខែនេះល្អមធ្យម។ ថ្ងៃនេះលោកអ្នកនឹងកើតការខ្វាយខ្វល់ផ្លូវចិត្តច្រើន។ ចំណែលកិច្ចការរកទទួលទានមិនមានប្រែប្រួលឡើយ។ រីឯការរស់នៅវិញ លោកអ្នកមានភាពផុយស្រួយ គួរប្រយ័ត្នប្រយែងឲ្យបានខ្លាំងក្លា។

**២.ឆ្នាំឆ្លូវ** រាសីខែនេះល្អមធ្យម។ បើចង់សំរុះសំរួល ឬណាត់ជួបអ្នកណាម្នាក់នោះ ច្រើនមិនជួបដូចបំណង។ ការប្រកបរបរជួញដូរមានភាពខ្យត់ខ្យោយ។ ការធ្វើដំណើរផ្លូវឆ្ងាយគួរប្រុងប្រយ័ត្ន។ជីវិតរស់នៅមានការមិនសូវចុះសម្រុងនឹងគ្នា។

**៣.ឆ្នាំខាល** រាសីខែនេះខ្ពស់ត្រដែត។ ការប្រកបរបររកស៊ីផ្សេង ៗទទួលបានជោគជ័យ។ ការធ្វើដំណើរកំសាន្តជួបតែសេចក្តីសុខក្សេមក្សាន្ត។ រីឯជីវិតរស់នៅក្នុងសង្គមគ្រួសារវិញ មានភាពរុះរាយនិងយល់ចិត្តគ្នា ហើយជាឪកាសល្អសំរាប់លោកអ្នកមានបំណងចង់រៀបចំគ្រួសារផងដែរ។

**៤.ឆ្នាំថោះ** រាសីខែនេះល្អបង្គួរ។ រយៈពេលនេះ កិច្ចការងារណា ដែលបំពេញខ្លួនឯងបានគួបញ្ចេញឲ្យអស់ពីកំលាំងកាយចិត្ត នឹងទទួលបានផលល្អ។ដំណើរចាកចេញក្រៅផ្ទះត្រូវប្រកាន់ចិត្តឲ្យនឹងធឹង។ ចំពោះការរស់នៅមានភាពផ្អែមល្ហែមដូចទឹកឃ្មុំ។

**៥.ឆ្នាំរោង** ដួងរាសីខែនេះល្អប្រពៃ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរមានភាពកាកកបល្អ អាចប្រមូលបានផលច្រើន។ ការធ្វើដំណើរជិតឆ្ងាយមានភាពសុខសាន្តដូចសព្វដង។សេចក្តីស្នេហាវិញមានសភាពស្រស់ស្រាយប្រៀបដូចត្រីនៅក្នុងទឹកនារដូវវស្សា។

**៦.ឆ្នាំម្សាញ់** រាសីខែនេះល្អជាមធ្យម។ចំពោះការប្រកបរបរជួញដូរប្រាក់ចំណូលរកបានដោយតានតឹងណាស់។ បើការចេញដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្នបន្តិច ក្រែងជួបគ្រោះថ្នាក់។ រីឯការរស់នៅក្នុងសង្គមគ្រួសារ មានភាពប្រទាំងប្រទើសគ្នាមិនសូវស្មើយប៉ុន្មានទេ។

**៧.ឆ្នាំមមី** រាសីខែនេះស្រុតចុះ។លោកអ្នកប្រកបការងារមានលំនឹងល្អ បើចង់បោះទុនរកស៊ីត្រូវប្រយ័ត្នបន្តិច ព្រោះផលតបស្នងមកវិញតិចតួចណាស់។បញ្ហាសង្គមគ្រួសារវិញនោះមានដំណើរថយក្រោយនិងជម្លោះវិវាទច្រើន។

**៨.ឆ្នាំមមែ** រាសីខែនេះខ្ពស់ត្រដែត។ ការជួញដូរផ្សេងៗនឹងទទួលបានជោគជ័យច្រើន ដូច្នេះលោកអ្នកត្រូវតែខិតខំប្រឹងប្រែង។ ចំពោះការធ្វើដំណើរវិញ មិនមានអ្វីមករារាំងបានទេ។ចំណែកការរស់នៅមានចំណងរឹងមាំល្អណាស់ហើយទោះបីមានអ្នកទី៣ចូលបំបែកក៏ពុំអាចធ្វើអ្វីកើតដែរ។

**៩.ឆ្នាំវក** ដួងរាសីខែនេះស្រុតចុះ។ ចំពោះលោកអ្នកប្រកបរបររកស៊ីមាមភាពខ្យត់ខ្យោយ។ការធ្វើដំណើរផ្លូវឆ្ងាយ ពុំសូវមានសុវត្ថិភាពទេ ប្រយ័ត្នឧប្បត្តិហេតុយាយី។ ចំណងអាពាហ៍ពិពាហ៍វិញនោះ មានការខ្វល់ខ្វាយច្រើន ព្រោះការមិនទុកចិត្តគ្នា។

**១០.ឆ្នាំរកា** រាសីខែនេះល្អជាបង្គួរ។ ដំណើរជីវិតប្រកបទៅដោយភាពសុខដុមនិងទទួលជោគជ័យជានិច្ច។ ចំពោះការប្រកបរបររកស៊ីជួញដូរនឹងបានផលជាទីគាប់ចិត្ត។ ចំពោះការរស់នៅ មានដំណើរជឿនលឿនទៅមុខគួសម។

**១១.ឆ្នាំច** រាសីខែនេះស្រុតចុះ។ ការធ្វើដំណើរចាកចេញទៅក្រៅផ្ទះ លោកអ្នកត្រូវប្រុងប្រយ័ត្ន គ្រោះថ្នាក់នឹងកើតមានឡើង។ រីឯជីវិតរស់នៅប្រចាំថ្ងៃ មានមិនសូវស៊ីចង្វាក់គ្នា គឺការប្រច័ណ្ឌនិងហួងហែងខុសបែបបទច្រើន។

**១២.ឆ្នាំកុរ** រាសីខែនេះល្អជាមធ្យម។ សំរាប់លោកអ្នកប្រកបរបររកស៊ីថេរល្អ។ការធ្វើដំណើរជិតឆ្ងាយគ្មានអ្វីជាឧបសគ្គទេ។ចំណែកក្នុងរង្វង់គ្រួសារ មានភាពរកាំរកូស និងភាពសៅហ្មងចាប់កំហុសគ្នាច្រើន។

# ហាងមាសមេគង្គ

# 湄江 MEKONG 珠寶

## JEWELRY



- **មានលក់មាសនិងពេជ្រគ្រប់ប្រភេទ**
- មានលក់គុជនិងត្បូងពេជ្រជាច្រើនសម្រាប់ធ្វើជាខ្សែក, ខ្សែដៃ, ក្រវិលនិងចិញ្ចៀន។ល។
- ទទួលរចនាគ្រឿងអលង្ការគ្រប់មុខគ្រប់ម៉ូដតាមការនិយមចូលចិត្តបែបបុរាណឬសម័យ។
- ទទួលជួសជុលគ្រឿងអលង្ការភ្លាមៗ !!!

សូមស្វាគមន៏អតិថិជនគ្រប់ទិសទី !!!

- **All Kinds of Diamonds & golds**
- COUNTLESS OF STYLES AVAILABLE FOR RINGS, NECKLACE, BRACELETS, ETC.
- WE ACCOMODATE ANY DESIGN THAT BEST SUITS YOUR INTERESTS.
- WE ARE MORE THAN HAPPY TO FIX OR REDESIGN YOUR PREOWNED JEWELRY.
- A VISIT TO OUR STORE WILL GUARANTEE YOUR SATISFACTIONS.

| ADDRESS: | KIM |
|---|---|
| 1954 ABORN ROAD | TEL: (408) 238-3377 |
| SAN JOSE, CA 95121 | FAX: (408) 238-2601 |